# ដំណាំខ្នុរ
# (Jackfruit)




ដោយ ប៉កភីឆុន វ៉ាយុអាត់សឌី
បកប្រែថតចម្លងលើកទី 4

**By Photpeechon Whayooathdee**
**Translation Copy No. 4**
**January 1997**

# ដំណាំខ្នុរ

| មាតិការឿង | ទំព័រ |
| --- | --- |
| 1. អ្នកណារំលឹករឿងខ្នុរ-ប្រវត្តិនៃដំណាំខ្នុរ | 1 |
| 2. ខ្នុរគួដាំឬទេ ? | 3 |
| 3. ខ្នុរជាឈើហូបផ្លែប្រវត្តិសាស្ត្រ | 7 |
| 4. ប្រភេទពូជខ្នុរសំខាន់ | 12 |
| 5. ការពង្រីកពូជខ្នុរ | 26 |
| 6. ការដាំដំណាំខ្នុរក្នុងចំការ | 32 |
| 7. ការតាក់តែងមែក | 39 |
| 8. ខ្នុរចូលចិត្តទឹក តែមិនធន់និងទឹកដក់ជាំឫស | 42 |
| 9. ការដាក់ជីលើដំណាំខ្នុរ | 46 |
| 10. ការថែរក្សាខ្នុរមុនពេលផ្តល់ផល | 51 |
| 11. ខ្នុរចាប់ផ្តើមផ្តល់ផល | 53 |
| 12. កត្តាចង្រៃលើដំណាំខ្នុរ | 57 |
| 13. ការប្រមូលផល | 63 |
| 14. ទីផ្សារ និងការប្រើប្រាស់ផលិតផលខ្នុរ | 65 |

# 1. អ្នកណារំលឹករឿងខ្នុរប្រវត្តិនៃដំណាំខ្នុរ

ការពិតក្រុមមនុស្សនៅភាគកណ្តាលបានយកចិត្តទុកដាក់ឈើដំណាំ “ ខ្នុរ ” យូរមកហើយដែលជាប្រភពបន្តពូជឈើនៅបាងកកតូច (បាងឃុននុន) ជាប្រភព បន្តពូជឈើផ្លែដែលធំបំផុតនៅពីមុននិងបច្ចុប្បន្ន ។ កន្លែងបន្តពូជខ្នុរនេះធ្វើការតមែកប្តូរពូជខ្នុរយូរមក ហើយក្រៅពីពូជឈើហូបផ្លែប៉ុន្មានប្រភេទដែលគេចាប់អារម្មណ៍យ៉ាងខ្លាំង ពីមុនមកនោះអ្នកចំការបានរួមដៃជាមួយអ្នកបច្ចេកទេសស្រាវជ្រាវរកពូជឈើផ្សេងៗទៀតជាគោលការណ៍ ។ បើមិនជួញ្ចោះទេអ្នកចំការមិនហ៊ុំហាផ្ចួអ្នកបច្ចេកទេសឡើយ ហើយបើមិនតាមអ្នកបច្ចេកទេសមិនមែនជាទេវតាក៏ដោយក៏ល្អជាង ការចេះតែដាំទៅមិនដឹងហេតុផលដែរ ។

លុះអ្នកបច្ចេកទេសបានសិក្សាស្រាវជ្រាវ ហើយបង្កើនដាំឈើប្រភេទណាមួយតាមការកំណត់របស់គេ ហើយបើមិនសិក្សាស្រាវជ្រាវឈើហូបផ្លែប្រភេទផ្សេងៗទៀតរវល់តែគិតទៅមកនៅត្រឹមតែប៉ុន្មាន ប្រភេទនោះថ្ងៃណាមួយនឹងកើតមានបញ្ហាជាមិនខាន ។ ព្រោះចំនួនអ្នកជាវិតតែច្រើន ជាហេតុពិបាករកទីផ្សារសំរាប់លក់ផលិតផល ។

ឈើផ្លែផ្សេងៗបានត្រូវសិក្សាស្រាវជ្រាវ និងបង្កើនអោយដាំច្រើនគ្នា ទាំងឈើផ្លែនៅក្នុងស្រុកនិងឈើផ្លែមកពីប្រទេសផ្សេងៗ តែនៅសល់ខ្នុរដែលភ្លេចពិនិត្យពីអ្នកបច្ចេកទេស ។ យើងត្រូវទទួលជឿជាក់ថាអ្នកបច្ចេកទេសកសិកម្មមាននាទីសំខាន់ ដែលពញាក់ការយកចិត្តទុកដាក់មនុស្សទូទៅអោយដាំពូជតែមួយប្រភេទ ឃើញថាពូជមួយប្រភេទដែលអោយមនុស្សចាប់អារម្មណ៍ពេលអ្នកបច្ចេកទេសផ្តល់រឿងសំខាន់ព្រមទាំងសុំអោយដាំទាំង ស្វាយ ធូរេន សាវម៉ាវ ភ្សៀវក្រូច ។ ឈើផ្លែទាំងនេះបានលេចមុខទៅដល់ថ្នាក់កំពូល ហើយក៏ ដោយសារការរួមដៃនិងគាំទ្រទាំងទ្រឹស្តីបច្ចេកទេសនិងការអនុវត្តន៍ ។

កាលពី ព.ស 2525 សាស្ត្រាចារ្យ ឌី ព្រមទាំង ឆៃយ៉ូងកៀន នៃមហាវិទ្យាល័យក្សេត្រសាស្ត្របានក្រោកឡើងពញាក់ស្មារតីអោយមនុស្សងាកមកចាប់អារម្មណ៍ដាំខ្នុរ ដំណាក់ការដំបូងចាប់ផ្តើម

ស្វែងរកខ្នុរពូជល្អៗ ផ្លែធំ ក្លែបក្រាស់ សាច់ច្រើន ស៊ីហើយឆ្ងាញ់យកមកសាកល្បងចិត្តមនុស្ស បន្ទាប់មកក៏បានខ្នុរល្អ នៅខេត្តប្រាជីនបុរី ឈ្មោះខ្នុរពូជ “ ហ្សាថាឡុម ” នៅចំការរបស់ស៊ីប៉ឹង ផ្ទុងថង ឃុំបានព្រាក់ ស្រុកមឿង ខេត្តប្រាជីនបុរី ។ ពីកន្លែងនេះបានចាត់ទុកជាកន្លែងចាប់ផ្ដើម ជារួបរាងរឿងខ្នុរតរៀងមក ។

គឺដោយជំហានដំបូងកាលពី ព.ស 2525 នេះហើយដែលមនុស្សម្នាផ្ដើមចាប់អារម្មណ៍ និង ស្គាល់ពូជខ្នុរ “ ហ្សាថាឡុម ” បន្ទាប់មកមានពូជ “ ចាំប៉ាក្រប ” ពូជ “ ដែងរស្មី ” ពូជ “ អ៊ុថ ” ។ រឿងខ្នុរពូជល្អទាំងនេះបានត្រូវផ្សព្វផ្សាយដល់អ្នកចំការនិងអ្នកចាប់អារម្មណ៍ ដាំជាបន្ត មករួមទាំងពូជខ្នុរ ដែលល្បីមកពីមុនដូចជា “តាប៊ួយ” ពូជ “ឃុនវិឆាន” និងពូជ “ដែងរស្មី” ដែលជាពូជបានត្រូវជាប់ក្នុងចិត្តមនុស្សមុននឹងត្រូវបោះបង់ចោល ឬបំភ្លេចទៅ ។



# 2. ខ្នុរគួរដាំឬទេ ?

ដំណាំប្រភេទនេះសំរាប់អ្នកចំការដែលជឿជាក់ ហើយគេយកចិត្តទុកដាក់រក្សាទុកជាកេរដំណែល ។ តែចំពោះកសិករដែលជឿនលឿន គេគិតរឿងបច្ចេកទេសជាមុន ហើយគេគិតថាកសិករដ៏ទៃទៀតដាំឈើផ្លែអ្វីដែលមានតម្លៃ ហើយកសិករនោះធ្វើដូចម្តេចបានល្អ ។ រីឯអ្នកចំការទូទៅដូចយើងរាល់គ្នាគ្រប់ៗរូបនោះត្រូវតែធ្វើទៅតាមសមត្ថភាពរបស់ខ្លួន ហើយបើមានចិត្តស្រឡាញ់ពីកំណើតនូវរឿងចំការនេះ ម្នាក់ៗត្រូវតែមានទំនាក់ទំនងជាមួយពួកអ្នកចំការដែលជឿជាក់ទាំងនោះ

ពាក្យសួរថា " ខ្នុរគួរដាំឬទេ ? " ត្រូវសួរថានរណាជាអ្នកដាំ ? បើអ្នកចំការនៅជនបទ ដាំមុខនេះគួរឆ្លើយបានថាត្រូវដាំដោយមានហេតុផលគឺ ÷

1. រុក្ខជាតិណាក៏ដោយអោយតែគេដាំត្រឹមតែមួយដង ហើយប្រមូលផលបានច្រើនសិបឆ្នាំក៏គួរតែដាំដូចនឹងផ្ញើរប្រាក់ចាំស៊ីការប្រាក់អញ្ចឹង ។

2. រុក្ខជាតិណាក៏ដាំបាន ហើយចុះដើមទុនថែរក្សាតិចនៅតែបានទទួលផលរុក្ខជាតិនោះក៏គួរដាំដែរតែបើរុក្ខជាតិណាដែលត្រូវចំណាយចាយវាយខ្ពស់ ហើយពុំសូវទទួលបានផលច្រើនក៏គួរកុំដាំ ។ ដោយឡែកចំពោះដំណាំខ្នុរជាឈើផ្លែស្ទើរពុំបាច់ប្រើជីគីមីសោះក៏បានទទួលលទ្ធផលល្អ ។

3. ផ្លែឈើដែលមានអាយុត្រូវបេះបានយូរអង្វែងរមែងគួរដាំជាងឈើផ្លែដែលចេញផ្លែ ហើយត្រូវបេះអស់ក្នុងពេលមួយដ៏ខ្លី លុះផុតរដូវត្រូវរង់ចាំឆ្នាំមុខទៀត ។ តែបើខ្នុរគឺអាចបេះបណ្តាក់ បេះបានតាំងពី 3-7 ខែ (បេះបណ្តើរលក់បណ្តើរ) ។

4. ឈើផ្លែប្រភេទណាក៏ដោយ ស្រេចតែអ្នកអាចផ្លាស់ប្តូរឆ្អែបរិភោគបានច្រើនយ៉ាងរមែងល្អជាងបរិភោគផ្លែទុំតែម្យ៉ាងគត់ដូចជាទៀប ត្របែក សាវម៉ាវ ធុរេន មង្ឃុត ។ល។ បើមិនចាស់និងមិនទុំគឺយកទៅបរិភោគមិនកើតសោះ ដោយឡែកចំពោះខ្នុរគឺអាចបរិភោគកើត

តាំងពីផ្លែខ្ចី ផ្លែចាស់ ផ្លែទុំ សូម្បីតែគ្រាប់ក៏បរិភោគកើតដែរ ហើយពេលទុំក៏គង់តែឆ្ងាញ់ មិនចាញ់ឈើហូបផ្លែប្រភេទផ្សេងៗទៀត ។

5. ឈើផ្លែដើមធំពេលដាំ អាចបង្កើតប្រយោជន៍ដល់សភាពបរិយាកាសបានច្រើន ជួយបន្ថែមកសាងសភាពព្រៃឈើដែលប្រទេសយើងខ្វះខាត ។ ខ្នុរជាឈើប្រភេទដើមធំគ្រប់ផ្នែករបស់ដើមអាចផ្តល់ប្រយោជន៍ដល់មនុស្ស និងសភាពបរិយាកាសបានយ៉ាងច្រើន ។ ការដាំដើមឈើធំដូចជាដើមខ្នុរត្រូវដាំឃ្លាតឆ្ងាយពីគ្នា ទើបអាចរកចំណូលបានច្រើនទៀតពីការដាំរុក្ខជាតិឆ្លោះដីទៀមផ្សំ ។ លើសពីនេះសូម្បីតែការចិញ្ចឹមសត្វនៅក្នុងចំការក៏យើងអាចធ្វើបានមែកចាងសាខាសំរាប់ជុត ។

ការដាំរុក្ខជាតិចន្លោះដិត ហើយដាំរុក្ខជាតិបានតែមួយប៉ុណ្ណោះ ៗ ដែលការធ្វើដូច្នោះអាចខូចជីវជាតិធម្មជាតិ តែបើផ្ទៃដីដែលដាំដើមឈើធំ ហើយមានរុក្ខជាតិឆ្លោះផងនោះគឺជាការបង្កើតធម្មជាតិបានយ៉ាងល្អ ។

6. បញ្ហាដែលអ្នកចំការជួបច្រើនគឺរឿងកម្លាំងការងារប្រមូលផល យើងយកមកគិតគណនាមើលថាឈើផ្លែដូចជា សាម៉ាវ ភ្សៀវ អំពិលផ្អែមឬផ្លែឈើផ្សេងៗច្រើនប្រភេទទៀត លុះដល់ពេលប្រមូលផលត្រូវប្រើមនុស្សចំនួនច្រើន បើមនុស្សនៅជិតខាងដាំឈើទាំងនោះតើនឹងរកមនុស្សណាមកបេះប្រមូលផល ។ ឧទាហរណ៍ដូចជា សាម៉ាវ ពេលណាដល់រដូវកាលបេះផ្លែរកកម្លាំង ការងារពិបាក ហើយថ្លៃខ្ពស់ឆ្នាំខ្លះតម្លៃលក់ស្មើរចាយសំរាប់ឈ្នួលបេះមិនគ្រប់ផង តែចំពោះខ្នុរមិនមានបញ្ហាចំពោះរឿងនេះឡើយ ។

7. ឈើហូបផ្លែច្រើនប្រភេទធ្វើអោយការពិនិត្យគ្រប់គ្រងផលិតផលពិបាក ឬអាចចោរលួចក៏មិនដឹងបញ្ហានេះពិតជាបញ្ហាធំព្រោកជ ដូចគ្នាការលះបង់ការងារធ្វើចំការបានច្រើនករណីណាស់ចំពោះខ្នុរពេលលួចពិបាកបន្តិចព្រោះផ្លែធំ ក្រៅពីនេះម្ចាស់ទៅពិនិត្យចំនួនផ្លែមួយដើមៗបានងាយ ។ ឈើផ្លែច្រើនប្រភេទត្រូវជួលកម្មករប្រមូលផលដូចជា សាវម៉ាវ ម្សៀន

មួយថ្ងៃៗប្រើកម្មករ 10 នាក់បេះបើកម្មករស៊ីក្នុងមួយថ្ងៃ 5 គីឡូ បេះ 20 ថ្ងៃត្រូវជា 100 គីឡូនិងឃើញថាមានការខូចខាតផលិតផលទៅប៉ុណ្ណាតែខ្នុរពុំកើតករណីដូចនេះជាច់ខាត ។

8. ការពិតខ្នុរនៅមានរឿងគួរចង់ដាំច្រើនថែមទៀត លោកអ្នកអានហើយល្បងគិត ហើយប្រៀបធៀបនិងឈើផ្លែផ្សេងៗ ដើម្បីជ្រើសរើសដូចជាខ្នុរមួយរ៉ៃដាំបាន 25 ដើម ផ្តល់ផលពេញទីក្នុងឆ្នាំ ទី 7-10 មធ្យមមួយដើមមាន 30-50ផ្លែ ហើយទម្ងន់មួយផ្លែ 15 គីឡូ តម្លៃលក់មួយគីឡូ 3 បាត ។

ផ្លែដីក្នុងមួយរ៉ៃ ទម្ងន់មធ្យមក្នុងមួយផ្លែ 15 គីឡូ និងបានប្រមាណ 11,250 - 15,000 គីឡូ តម្លៃមធ្យមក្នុងមួយគីឡូក្រោម 3បាត គិតជាប្រាក់ក្នុងមួយរ៉ៃលក់បាន 33,750-45,000 បាត ។

បើតួលេខនេះនៅខ្ពស់ពេកយើងងាកមកមើលតួលេខទាបៗ គឺលក់ខ្នុរចេញពីចំការត្រឹមតែមួយគីឡូក្រោមមួយបាត យើងក៏គង់នៅមានចំណូលបានក្នុងមួយរ៉ៃទាបជាង 11,250-15,000 បាត ក្រៅពីនេះចំណូលបានពីការដាំរុក្ខជាតិឆ្លោះរវាងដើមខ្នុរនៅមិនទាន់បានគិតផង ។

គិតៗទៅខ្នុរគួរជាវិយការបៀបនេះ បើតួលេខដែលខ្ញុំលើកយកមកនេះមិនសំខាន់ទេ ម៉្យាង ក៏តួលេខរបស់ “ ព្រះយ៉ាវវែត ផុងសាវិសុទ នាធិបតី ” ដែលបានគណនាចំណូលដាំខ្នុរមួយរ៉ៃសរសេរចុះក្នុងសៀវភៅកសិករច្បាប់ទី 6 ឆ្នាំទី 35 (ប្រមាណព.ស 2504) លោកបានអោយតួលេខថាខ្នុរក្នុងមួយរ៉ៃដាំបាន 30 ដើមផ្តល់ផលក្នុងមួយដើមប្រមាណ 50 ផ្លែ (មួយរ៉ៃបាន 1,500 ផ្លែ) លក់បានមួយផ្លែ 5 បាត រួមជាប្រាក់ 7,500 បាត ក្នុងមួយរ៉ៃក្នុងមួយឆ្នាំ (តែក្នុងបច្ចុប្បន្នខ្នុរមួយផ្លែមិនទាបជាង 10 បាតទេ) ។

កាលពី 25 ឆ្នាំមុនដាំខ្នុរបានមួយរ៉ៃ 7,500 បាតចំណូលនៅតែល្អជាងធ្វើស្រែសម័យនេះច្រើនដង “ព្រះយ៉ាវវែតផុងសាវិសុទនាធិបតី” នៅសរសេរក្នុងអត្ថបទទុកថា ÷

សិស្សដែលរកការមិនបានធ្វើ សុំណែនាំទៅអោយធ្វើចំការខ្នុរបួនដប់អ៊ែរយៈពេលដល់ 10 ឆ្នាំ លោកនិងមានអារម្មណ៍សប្បាយចិត្តច្រើន ជាងពួក ដែលធ្វើការងារទទួលប្រាក់ខែជាប្រាកដ ហើយក្នុងរវាងដែលខ្នុរនៅមិនទាន់ផ្តល់ផលលោកនិងរកផលប្រយោជន៍ពីដំណាំឆ្លោះ
បានយ៉ាងច្រើន បើ ធ្វើល្អជាងខ្នុរនិងចេញផលទៅចិញ្ចឹមខ្លួនបាន ។



# 3. ខ្នុរជាឈើហូបផ្លែប្រវត្តិសាស្ត្រ

ចំការក្នុងស្រុកសុខោថៃបានបង្កើត ព្រៃស្វា ព្រៃម្ទូ ព្រៃផ្ទង់ក៏ច្រើន ព្រៃខ្នុរក៏ច្រើនស្វាយក៏មានច្រើននៅក្នុងស្រុកនេះពេញរណាជារុក្ខជាវា ។

សេចក្តីខាងលើជាឃ្លាមួយក្នុងបង្គោលសិលាចារិកពោលដល់រុក្ខជាតិប្រាំប្រភេទគឺ ស្វា ម្ទូ ផ្ទង់ ខ្នុរ ស្វាយ ឬរមបូរាណមិនមែនជារឿងធម្មតាទេ ចំពោះរុក្ខជាតិដូចទាំងប្រាំប្រភេទនេះ ។ ខ្នុរដូចជាស្គាល់ទូទៅទាំងអស់គ្នាតែសូមជ្រាបខ្នុរចែកចេញជាពីរប្រភេទធំៗគឺ ÷

1. **ខ្នុរចំប៉ាដាក់ :** ជាខ្នុរដែលមានផ្លែបក្រាស់ពណ៌លឿង ក្រហមតិចៗដូចជាផ្កាចំប៉ាមានឈ្មោះវិទ្យាសាស្ត្រថា *Artocarpus champenden* និយមដាំច្រើននៅភាគខាងត្បូងប្រទេសថៃ

2. **ខ្នុរណាំង :** ជាខ្នុរដែលមានឈ្មោះវិទ្យាសាស្ត្រ *Artocarpus integra* ឬ *Artocarpus integrifolia* ពេលទុំសាច់ច្រើនរឹង ភាសាម៉ាឡេយូហៅថា ណាំងកាក់ ឃើញថ្មេះទើបនាំគ្នាហៅថាខ្នុរណាំង

ជនជាតិម៉ាឡេយូចែកខ្នុរ ណាំង ចេញជាពីរជំពូកគឺ បើសាច់ណែន ស្ងួយហៅថា ណាំងកាក់បេលុបាំង ហើយបើប្រភេទសាច់ក្រាស់ ទន់ហៅថាណាំងកាក់បបរ ឬអ្នកស្រុកពីណាំងហៅថា " ចំប៉ាក់ដាក់ម៉ាន់ផង " ។

ស្រុកថៃមានខ្នុរមួយប្រភេទទៀតពេលទុំហើយសាច់ ជ្រាយសំបកទន់ ហៅថាខ្នុរល្អិត ខ្នុរប្រភេទនេះនិងជ្រាបជាមួយណាំងកាក់បបរ របស់ម៉ាឡេយូ ឬ ចំប៉ាដាក់មាន់ងងរបស់ពីណាំងបានទេដឹង ?

រឿងពូជខ្នុរនៅពុំទាន់ចប់ត្រឹមនេះទេ នៅមានសេចក្ដីសរុបរបស់ ម៉ាប៉ារ៉ាត់ឡេ ក្នុងសៀវភៅអក្សរាភិធានសំស្ក្រឹតបានសរសេរថា " ខ្នាន់គួរ និងខ្នុរ " តែពុំទាន់ មានពាក្យអធិប្បាយក្រៅពីនេះជួយគ្នាស្មានខ្លួនឯង ។

ក្នុងព.ស 2503 បានសរសេរទុកក្នុងសៀវភៅកសិករថា មានពូជថ្មីចម្លា នេះដែល ភាគខាងត្បូងហៅថា " ខ្នូន " នាយផុចសរសេរ តទុកថា ជាខ្នុរមួយប្រភេទក្នុងខណៈដែលមានផលផលនិងនៅក្នុងដី ហើយចំការនោះនិងបែកចេញពេលផ្លែទុំមានក្លិនក្រអូបល្ហួយ ចេញមកពីរណ្ដៅ ហ្វុំ និងសត្វល្អិតផ្សេងៗទៀតដែលរោរ ម្ចាស់និងបានដឹងថាខ្នុរបានទុំ ហើយសន្សំឆ្អៃយកករទៅជីកដីចេញហើយកាត់ទាំងផ្លែយកទៅបរិភោគ ។

គ្រូវង្ស បុណ្យរុត អ្នកដែលចាប់អារម្មណ៍ក្នុងរឿងដើមលើសម័យនោះ (ប្រមាណ ព.ស 2503) ពោលថាជាខ្នុរចម្លែតនោះឯង ព្រោះមានពូជមួយឈ្មោះតាចិនបានទទួលបញ្ញាអោយដាំទូទៅក្នុងដីភ្នំ ចំការអាំផន ។ល។ ចែកយកទៅដាំតាមចំការតាមតំបន់នោះនៅវត្តខេម៉ាផិតរាម ក៏មានខ្នុរតាចិនមានដើមទាប ស្លឹករលើប ចុងទន់ ធាងស្លឹកវែងផ្លែក្នុងដី មានទឹកក្នុងផ្លែបសាច់ក្រាស់ពណ៌លឿងខ្ចី ហើយផ្អែមតិច ។

ក្រៅពីខ្នុរតាចិន ហើយមានខ្នុរពូជមួយដែលធ្លាប់និយាយថាជាខ្នុរមានឈ្មោះ " តាបួយ " ជាខ្នុរណាំពណ៌ចំប៉ាធ្លាប់នាំយកទៅប្រកួតបានទទួលរង្វាន់ទីមួយ ក្រៅពីនេះនៅមានដើមមួយទៀតដែលផុងសារិសុខធិបតីដាំទុក ផ្លែបមូលបន្តិចមានទឹកក្នុងផ្លែបខ្លះ សាច់ពណ៌ចំប៉ាខ្ចី ជាខ្នុរ ល្អដូចគ្នា ។

ចំពោះខ្នុរក្នុងដីដែលបក្សខាងត្បូងហៅថា " ខ្នូន " នោះបណ្ឌិត អាត់ ណាខនថាប មិនជឿថានៅជាអ៊ីចឹងបានឡើយ ថែមទាំងអធិប្បាយរឿងការផ្សំពូជអោយស្ដាប់ថាមានគំរូមកដូចជាសំបកដីព្រែងជាពូជមួយផ្សេងទៀតតែនៅស្រាប់តែមកហៅថាខ្នុរក្រៅពីនោះនៅមាន "ខ្នុរសាំប៉ាក់ឡ" មួយប្រភេទទៀតចាត់នៅក្នុងត្រកូលដូចគ្នាមានឈ្មោះ វិទ្យាសាស្ត្រថា *Artocarpus communis* (ឬ *A. incisa* ) ភាសាម៉ាឡេយូ ហៅថា " កាក់ឡី " ឬ " កាក់ឡ " ភាសាត្មិលហៅថាខ្នុរ " សាក់កិ " ។



សេចក្តីសរុបទាក់ទងនិងប្រវត្តិសាស្ត្រ រឿងខ្នុរនិយាយមកដូចខាងលើនេះខ្ញុំធ្លាប់អានជួបក្នុងសៀវភៅ "រុក្ខជាតិនិងសត្វដែលចាប់អារម្មណ៍" សរសេរដោយឈ្មោះ " ឆ.ស " (សៀវភៅមកពីមហាវិទ្យាល័យកសិកម្មត្រសាស្ត្របាងខែងបោះពុម្ព ព.ស 2503-2505 បើខ្ញុំថាមិនខុស) ។

ឈ្មោះខ្នុរ តែមិនហៅដូចគ្នាទេភាគកណ្តាលហៅថា " ខ្នុរ" ភាគខាងជើងហៅថា " ម៉ាក់នុន" ភាគខាងកើតឆៀងខាងជើងហៅថា " ប័កមាន " ភាសាខាងត្បូងហៅថា " នុន " (ពាក្យនេះហើយអាចហៅ ខនដូរខាងត្បូង) ម៉ាឡេយូហៅថា " ណាំងកា " ចិនហៅ ថា " ប៉ាំងកា " ភាសាអង់គ្លេសហៅថា " Jack-fruit " ភាសាឡាតាំងហៅថា *Artocapus integra* (Thunb.) Merr. ។

ផលប្រយោជន៍របស់ខ្នុរក្រៅពីទទួលទានផ្លែខ្ចី ទុំ ហើយដើមខ្នុរអាចធ្វើអ្វីៗផ្សេងៗ ដូចជាខ្លឹមខ្នុរយកទៅស្ងោរយកទឹកជ្រលក់ក្រណាត់ ហើយដែលពិសេសទៀតគឺដើមខ្នុរគេនិយមធ្វើគ្រឿងតន្ត្រីមួយប្រភេទគឺ តាពេ ព្រោះតាពេដែលល្អបំផុតត្រូវបានធ្វើពីដើមខ្នុរ ។

ជា ផ្លែឈើដែលធំ បំផុតក្នុងបណ្តាឈើប្រភេទផ្សេងៗក្នុងលោកនេះក៏ថាបានច្រើនទើបហៅថា " Jack-fruit " ក្នុងបច្ចុប្បន្ន ដែលយើងបែងខ្នុរជាបីក្រុមផ្សេងគ្នាគឺ ÷

**ខ្នុរណាំង** ប្រទះច្រើនបំផុតលក្ខណៈទូទៅមានសំបកស្តើត មានក្លែបច្រើនមានក្លែបជាប់គ្នា និងស្នូលកណ្តាល ហើយម្យ៉ាងទៀតក្លែបនៅជាប់ សំបកយ៉ាងជាប់សាច់របស់ក្លែបស្តើត ឬស្រួយពណ៌របស់សាច់មានទាំងពណ៌ស លឿងខ្ចី លឿងចាស់ និងពណ៌ចំប៉ា ភាគច្រើនពណ៌របស់សាច់ជ្រាំងច្រើនជាពណ៌ដូចគ្នាតែមានខ្លះដូចគ្នា ឯពណ៌ផ្សេងៗគ្នាពណ៌សាច់ក្លែបដែលមាននៅក្នុងក្រុមនេះគឺពណ៌លឿងចាស់ និងពណ៌ចំប៉ា ។

លក្ខណៈខ្នុរណាំងដែលល្អ គឺលក្ខណៈផ្លែមូលវែង ស្នូលឬជ្រាំងកណ្តាលវែងតូចក្លែបក្រាស់ពណ៌លឿង ឬចំប៉ាក៏បាន

ខ្នុរណាំងសាច់ពណ៌ លឿង សាច់វែងក្រាស់ជាងណាំងពណ៌ចំប៉ា សាច់ក្លែបស្រួយហើយឆ្ងិតល្អមសាច់ក្លែបស្ងួតមិនជ្រាយ ខ្នុរណាំង សាច់ពណ៌លឿងពេលស៊ី ក្លិនជាប់ក្រមុះ ។

ក្រុមខ្នុរល្មុត ជាទូទៅបើផ្លែមិនទុំ មើលទៅដូចខ្នុរណាំង តែពេលទុំបន្លានិងសំបកផ្លែទន់ ។ បើយកម្រាមដៃសង្កត់ចុះទៅលើសំបកផតចុះទៅដល់សាច់ ហើយជ្រាំងទន់ស្អិតក្លែបមិនក្រាស់ ហើយមិនធំរស់ជាតិផ្អែមមានក្លិនខ្លាំងជាងខ្នុរណាំង ។ គេមិននិយមដាំតែគ្រាប់គួរយកបណ្តុះធ្វើជាដើមត ។

ក្រុមខ្នុរចំប៉ាដាក់ ប្រទះច្រើនបំផុតភាគខាងត្បូង ដើម ស្លឹក ផ្លែ ស្រដៀងខ្នុរណាំងណាស់ ផ្លែតូចជាងខ្នុរ ផ្លែវែងបន្លាយផ្លែតូច សំបកស្តើង មានក្លែបតិច (ពេលទុំស្ទើរពុំមានជញ្ជ្រាំង) ពេលទុំសំបកហែកបានស្រួលក្លែបជាប់គ្នានិងជ្រាំងមិនណែន ក្លែបមិនតោងជាប់និងសំបកពេលពុះរបេះសំបកចេញសំបកនិងក្លែបចែកចេញពីគ្នាតាច់ជ្រាយបន្តិច រស់ជាតិផ្អែម ក្រអូបណាស់ អាចយកជញ្ជ្រាំងទៅជ្រលក់ម្សៅចៀនស្រដៀងទៅនិងចេកចៀន ផ្តល់ផ្លែពេញក្នុងដើមនិមួយៗ និយមបរិភោគនៅភាគខាងត្បូង ។

ក្នុងខ្នុរបីក្រុម ដូចបានរៀបរាប់នោះ ខ្នុរណាំងជាសេដ្ឋកិច្ចទូលំទូលាយក្នុងខណៈដែលចំប៉ាដាក់ជាខ្នុរសេដ្ឋកិច្ចភាគខាងត្បូងរហូតមក ។

# 4. ប្រភេទពូជខ្នុរសំខាន់

លោក ស៊ុនថន ប៉ុនណុថុក ធ្លាប់បាននិយាយថា ខ្នុរដែលល្អ ពេលណាស៊ីចូលទៅក្នុងបំពង់ក ហើយមានក្លិនក្រអូបដូចផ្កា ម៉ុនថារី ចេញមកតាមច្រមុះ ហើយតទៅកាលណារកពូជខ្នុរដាំ សូមអោយយល់ថាជា “ខ្នុរណាំង” ដែលមានច្រើនពូជ ផ្សេងៗគ្នាខ្នុរពូជ “តាបួយ” ។

សូម្បីជាមានពូជខ្នុរល្អៗរួមជំនាន់រួមសម័យនិងពូជ “ តាបួយ ” ក៏ដោយក៏មានច្រើនពូជទៀតដូចជា “ ពូជតាចិន ” តែពូជទាំងនេះស្ទើរសាបសូន្យអស់ទៅហើយ ឬអាចមានលំអាននិងលក្ខណៈអោយប្រាកដច្បាស់លាស់ពិបាក និងបានគង់វង្ស “ ពូជតាបួយ ” ត្រឹមតែមួយពូជដែលជាខ្នុរល្អពីបុរាណដែលគង់វង្សនៅរហូត មកដល់បច្ចុប្បន្ន ហើយពូជតមកក្លាយជាពូជផ្សេងៗទៀតច្រើនសន្ធឹក ចំពោះពូជតាបួយដែលដាំនៅក្នុងខេត្តប្រាជីនបុរី មកបណ្តុះគ្រាប់ហើយក្លាយជាពូជ “ ហ្វាថាឡុម ” ដែលពូជនេះបច្ចុប្បន្នកំពង់ គេស្គាល់ច្រើន ។

សេចក្តីសរសើររបស់ពូជខ្នុរតាបួយនោះនៅពុំទាន់ច្បាស់លាស់ តាមអ្នកដែលបញ្ជាក់ទុកពីរនាក់គឺ មហាឆិម បញ្ជាក់ថាយកពូជមកពីក្រុម 8 តំបន់បាំងកក ខេត្តរាជបុណធនៈបុរី មានអាយុប្រមាណ ៦០ ឆ្នាំ លក្ខណៈដើមមានតែស្លឹកធំហើយក្រាស់រលើប ស្លឹកមិនរួមគេតែមួយមានទ្រុង រន្ធចប៉ុណ្ណោះ ។

លក្ខណៈផ្លែរាងជាព្រលុង្គឹមព្រាំ ត្រសៀងទៅនិងប្លាក់តារាំង មានផ្លែច្រើនពី 20 - 80 ផ្លែ ក្នុងមួយដើម បើផ្សំពេសរជាប់បានល្អនិងពុំមានកំពិតកំពៀវតិស្មើគ្នា គ្រប់ជ្រុងជ្រោយបន្ទាធំ សាច់លឿងមធ្យម ស្បែកស្តួតស្រួយ គ្រាប់តូច ជ្រាំងវែងបន្តិច ហើយជាពូជខ្នុរដែលធន់និងដីរអាគុំជ បានល្អ ។

តែគោលសេចក្តីរបស់ គុណវិស្ងត បានអះអាងថាខ្លួនជាចៅតាបួយ (ម្ចាស់ដើម) បានអះអាងថា ដើមមុនជាដើមពូជហៅថា ចំប៉ាដាក់តែភាគច្រើនហៅថាជាខ្នុរតាបួយតាមឈ្មោះម្ចាស់ខ្នុរដែល

មានក្លែបនិងជញ្ជ្រាំងពណ៌ចំប៉ា មិនមែនពណ៌លឿង រស់ជាតិផ្អែមតែមិនខ្លាំងទេ បើចិញ្ចឹមផ្លែទុកទល់ចាស់ផ្លែច្រើនបែក បើមិនចាស់ជញ្ជ្រាំងពណ៌ស ហើយបច្ចុប្បន្នខ្នុរពូជនេះគុណវិសេសពានព្រាប់ថារកពិបាកណាស់ ។

តែជាពេលដែលជាគួរសង្កេតថាប្រវត្តិខ្នុរពូជតាប៉ួយនេះពេក រភាត់ណាខនតការ (អះអាងតាមអ្នកប្រើឈ្មោះថ្មីថា ឆ.ស ក្នុងសៀវភៅរុក្ខជាតិនិងសត្វ) ជាក់លាក់ថាជាខ្នុរណាំងពណ៌ចំប៉ាដែលឈ្មោះប្រកាន់បានថាពីដើមជាខ្នុរតាប៉ួយ ជាខ្នុរណាំងសាច់ពណ៌ចំប៉ា តមកបណ្តុះគ្រាប់ ហើយក្លាយជាពូជខ្នុរណាំពណ៌លឿង ហើយសាច់ពណ៌លឿងជាសាច់ពណ៌ចំប៉ា ហើយក្លាយជាពណ៌លឿងទៀត ទោះជាយ៉ាងណាក៏ដោយខ្នុរតាប៉ួយដែលអះអាងនិងមិនមានដើមពូជដែលល្មមរកបានក្នុងពេលបច្ចុប្បន្នសុទ្ធតែសាច់ពណ៌លឿងទាំងអស់នោះទេ នៅពុំទាន់ប្រាកដថាតាប៉ួយដែលដាំឥឡូវនេះមានសាច់ពណ៌ ចំប៉ាសល់នៅឯណាទៀតខ្លះ ។

ខ្នុរពូជហៀថាឡុម

កាលប្រមាណ 65 ឆ្នាំដែលកន្លងផុតទៅ ខុនផ្គុងចិនភក្តី យល់ថាជាដើមត្រកូល "តារិកាភូតិ" គ្រានោះខុនផ្គុងបានយកខ្នុរតាប៉ួយពីបាងកក ហើយយល់ថាយកមកពីបាងកកតូចទៅដាំផ្ទះនៅខេត្តប្រាជីនបុរី ដោយប្រើគ្រាប់ចំនួនច្រើន តែមានពីរដើមមិនដូចដើមមុន (តាប៉ួយ) ។

មានមួយដើមនៅក្នុងចំការមានលក្ខណៈដូចខ្នុរតាប៉ួយផ្លែមូលធំដូចបាល់ទាត់ក្លែបក្រាស់ តែមានក្លែបពណ៌លឿងជំនួសពណ៌ចំប៉ាដូចដើមមុនផ្លែតាប៉ួយ ដើមនោះពេលផ្លែគ្រាប់ច្រើនដុះតាំងពីពេលផ្លែទុំធ្វើអោយក្លិនមិនល្អភាពផ្អែមថយចុះដើមនេះហៅថា "ហៀថាឡុមដើមក្នុង" ព្រោះអាស្រ័យក្នុងចំការភាគខាងត្បូង ។

មួយដើមទៀតគឺ "ហៀថាឡុមដើមក្រៅ" បច្ចុប្បន្នពេលនិយាយដល់ខ្នុរពូជហៀថាឡុមជាទូទៅមានន័យដល់ហៀថាឡុមដើមមានលក្ខណៈច្បាស់ លាស់គឺក្លែបមានពណ៌លឿង រូបរាងផ្លែដូចស៊ុត



(ពាប្លយផ្លែបូលេ) ផ្លែធំ ក្លែបក្រាស់ រសជាតិផ្អែមឆ្ងាញ់ ភាពផ្អែមខ្ពស់ស្រួយរន្ធិច ដ្បាតរបស់ក្លែបមិនថាផ្លែតូច ឬផ្លែធំក្លែបក្រាស់ ហើយធំជានិច្ចមានជ្រាំងមធ្យម ។

សម័យនោះខ្នុរត្រូវអ្នកដាំភ្លេចឈឹង ខ្នុរដើមនេះក៏ដូចគ្នាមានផ្លែមកតាំងពីរដូវភ្លៀងរហូតដល់ភ្លៀង ហើយនៅមិនទាន់មាននណាទៅកាត់យកមកស៊ីទៀត ផ្លែក៏ធំឡើងទៅជារៀងរាល់ថ្ងៃ មាននៅយប់មួយភ្លៀងធ្លាក់យ៉ាងខ្លាំង មានព្យុះបក់ខ្លាំងបង្អួរ តែខ្លាំងល្មមធ្វើអោយខ្នុរនោះរបេះចុះមកបាន ខណៈដែលវារបេះចុះមកដីនោះផ្លែខ្នុរដែលពុំបានបេះនោះរមែងធំឡើងធ្លាក់ប៉ះដីដូចជាសម្លេងបាវធ្លាក់ មនុស្សដែលបានឮយល់ថាជាសម្លេងផ្គរលាន់ តែពេលភ្ញាក់ព្រឹកឡើងម្ចាស់ទៅជួបផ្លែខ្នុរជ្រុះពេញដី ផ្លែបែកខ្ទេច ទើបដឹងថាសម្លេងយប់មុិញជាសម្លេងខ្នុរធ្លាក់ដីសោះ ។ ដូច្នេះហើយទើបមិនដាក់ឈ្មោះថាខ្នុរពូជ " ហ្មាថាឡុម " ។ ខ្នុរហ្មាថាឡុមជាខ្នុរដែលក្លែបក្រាស់មានជ្រាំងមធ្យមក្លែបធំ ហើយជាខ្នុរពូជធ្ងន់ជាងពូជផ្សេងៗផ្តល់ផលមិនច្រើនទេ ។

កាលពី ព.ស 2484 អ្នកធំនៅតំបន់បាងព្រាក់ ធ្លាប់យកពូជខ្នុរនេះបញ្ចូលចូលប្រកួតនៅឯបាងកក ក្នុងពិធីបុណ្យពូជមង្គលនៅវាល ។ ផ្លែខ្នាត 36 គីឡូក្រាម ព្រាកដថាបានទទួលរង្វាន់ទីមួយពីលោកចមពលផ្លែក ភិប៊ូនសង្គ្រាម ជាមាសមួយបន្ទះរាប់ថាជាខ្នុរល្អយូរយារមកហើយ ។

## ពូជខ្នុរថងសុតចៃ

អំពីការតាមដានផលដែលរីកចំរើន និងគុណសម្បត្តិល្អរបស់ពូជខ្នុរនេះសេចក្តីគួរចង់ដាំមានច្រើនជាងពូជហ្មាថាឡុម ។

ពូជហ្មាថាឡុមនោះពិតជាល្អបំផុតចំពោះអ្នកស៊ី ព្រោះក្លែបធំវែងក្រាស់តែមិនសូវផ្លែ ផលិតផលក្នុងមួយដើមនោះមិនល្បះ " ថងសុត ចៃ " ទេ ដោយខ្នុរពូជថងសុតចៃនោះមានផ្លែច្រើនជាងសាច់ក្រាស់អាចទប់ទល់និងហ្មាថាឡុមបានដូចគ្នា ពេលដែលហ្មាថាឡុម ផ្តល់ផលមិនសូវបានច្បាស់លាស់ "ថងសុចចៃ" ផ្តល់ផលច្រើនជាងផ្តល់ចំណូលអោយដើមនិមួយៗមិនទាបជាងមួយពាន់បាតទេ មិនធ្លាប់ខាតសោះក្នុងមួយឆ្នាំៗ ។

លក្ខណៈប្រចាំពូជ ចតសុតថៃ ដែលលេចធ្លោ គឺមានផ្លែច្រើន ក្លែបក្រាស់ (តែក្រាស់តិចជាង ហ្វាថាឡុមបន្តិចបន្តួច) សាច់ក្លែបពណ៌លឿងចាស់ ស្ងួយ ផ្អែមអន់ជាង ហ្វាថ្លុមបន្តិចបន្តួច គ្រាប់តូច សំបកស្តើង ជ្រាំងតិច ស្លឹកចាប់មើលច្រាស់ដៃតិចៗ ស្លឹកមិន មូលដូច ហ្វាថាឡុម ផ្លែមូលសមគួរ ។ លោក គៀតិគុណ បានធ្លាប់ទទួលរង្វាន់ពីការប្រកួតខ្នុរស្មើរាល់ឆ្នាំ ទម្ងន់ ប្រមាណ 8 - 29 គីឡូក្រាម ។

ពូជចំប៉ាក្រប

ខ្នុរនេះមានក្លែបពណ៌លឿង និងពណ៌ចំប៉ាគួរអោយចង់បរិភោគបើបានឃើញពណ៌ហើយមនុស្ស ភាគច្រើននិយមបរិភោគពណ៌ចំប៉ាច្រើនជាង តែខ្នុរក្លែបពណ៌ចំប៉ាមានតិច យើងនិងឃើញបាន ថាអ្នកជំនួញប្រមូលខ្នុរក្លែបពណ៌លឿងលក់ភាគច្រើនមួយឆ្នាំៗរកស៊ីក្លែបពណ៌ចំប៉ា បានពុំសូវញឹក ញាប់ទេ ។

ប្រវត្តិខ្នុរពូជនេះបន្តឈ្មោះមកពីពូជតាបួយដោយត្រង់តែក្លាយពីពូជ មកពីការបណ្តុះគ្រាប់របស់ ហ្វាថាឡុមដើមក្រៅជាចៅតាបួយ និងឃើញបានថាខ្នុរនេះមកពីពូជក្លែបលឿង " ហ្វាថាឡុម " មកជាពណ៌ចំប៉ា ដូចពូជតាបួយដើមមុនម្តងទៀត ។

លក្ខណៈប្រចាំពូជជាខ្នុរក្លែបពណ៌ចំប៉ា សាច់ក្លែបមិនក្រាស់ តែក៏មិនស្តើង ពូជពណ៌ចំប៉ានោះ ក្លែបក្រាស់ទប់ទល់និងពូជពណ៌លឿងមិនបាន លក្ខណៈលេចធ្លោគឺសាច់ស្ងួយផ្អែមឆ្ងាញ់សររ និងពូជឈ្មោះ សូម្បីទុំបេះទុកច្រើនថ្ងៃសាច់ក៏មិនជ្រាយអាចទុកបានយូរជាងពូជផ្សេងៗទៀត ។

ផ្លែច្រើនមធ្យម ស្លឹករលើបពណ៌ខៀវចាស់ ទុងស្លឹកស្រួច ផ្លែមិនសូវមូល លក្ខណៈផ្លែមិនធំ ភាគច្រើនរាងផ្លែមិនល្អ ។

ទ្រង់ទ្រាយដើមទាបជាងខ្នុរពូជផ្សេងៗរភាគដាំចន្លោះ 6 x 6 ឬ 7 x 7 ម៉ែត្របាន ។

បើយកខ្នុរទាំងបីពូជ និងផ្លែបអោយជ្រើសរើសតាមរសជាតិចូលចិត្តរបស់មនុស្សទូទៅ និងជ្រើសរើសយកពណ៌ចំប៉ាមុន ចំប៉ាស្រួយ ផ្អែម មធ្យម មិនផ្អែមខ្លាំង តែវាមិនសំខាន់លក្ខណៈលេចធ្លាស់ដែលស្រួយឆ្ងាញ់ សន្មត់ថាលោកបរិភោគខ្នុរហ្សថាឡុមបានកន្លះគីឡូ តែបើខ្នុរចំប៉ាក្រប លោកនិងបរិភោគបានច្រើនជាង ។

## ពូជខ្នុរ អ៊ីថរខៀវ ថរដែង ថរចំប៉ា

ក្នុងចំណោមឈ្មោះខ្នុរដ៏ច្រើនសន្ធឹកសន្ធាប់ គេរើសយក "ហ្សថាឡុម" តែបើតាមរូបរាងពណ៌សណ្ឋានប្លែក ហើយគេត្រូវការគួរជ្រើសរើសពូជ "អ៊ីថរ" លោកឃើញខ្នុរគឺតថាយកមានន័យថាចូលចិត្តទៅហើយ ។

ប្រវត្តិពូជនេះកើតមក គឺក្លាយមកពីពូជ "តាឬយ" ប៉ុន្តែក្លាយមកស្ទើរភ្លេចពូជបាត់ទៅ ហើយពូជរបស់តាឬយផ្លែមូល ឬពូជអ៊ីថរវិញក្លាយជាផ្លែវែងប៉ុន្តែវាត្រឡប់មកជាផ្លែខ្លីវិញ ព្រោះកាលណាបំបែកពូជទៅគឺផ្លែកាន់តែខ្លីទៅ ។

ខ្នុរពូជអ៊ីថរ មានពូជ "អ៊ីថរក្រហម" មានសំបកពណ៌ក្រហម ឬពណ៌ស្ពាន់ចាស់ "អ៊ីថរពណ៌ខៀវ" មានសំបកពណ៌ខៀវពេលទុំនៅតែមានពណ៌ខៀវ "អ៊ីថរចំប៉ា" មានសំបកខៀវ ភ្លែបពណ៌ចំប៉ា ភ្លែបរបស់អ៊ីថរក្រហម និងអ៊ីថរមានពណ៌លឿង ។

ជាខ្នុរផ្លែវែង ភ្លែបវែង សាច់រលើបក្រាស់ ស្រួយ ប៉ុន្តែអ៊ីថរខៀវ ភ្លែបខ្លី មានរសជាតិល្អជាងអ៊ីថរចំប៉ានិងអ៊ីថរក្រហម កាលណាបើប្រៀបធៀបជាមួយពូជផ្សេងៗលក្ខណៈរបស់ភ្លែបរស់ជាតិភាពផ្អែមនោះធន់និងពូជផ្សេងៗមិនបានល្អ ។ តែបើធ្វើការកាត់តែងមែកអោយស្រឡះ និងបានទទួលផលច្រើនដើមអាយុ 7-8 ឆ្នាំ អោយផលរហូតដល់ 40 ផ្លែ ទំហំវែង ទម្ងន់ប្រមាណ 10 គីឡូក្រាម ក្នុងមួយផ្លែជាពូជដែលផ្តល់ផលបានយ៉ាងឆាប់រហ័ស ហើយអាយុកាន់តែចាស់រឹតតែផ្លែច្រើនដែរ ។

## ពូជខ្នុរដែងរស្មី

ខ្នុរគ្រប់ពូជដែលបាននិយាយមកនោះ ជាពូជដែលជាចំការនាយ ស៊ីប៉ង នៅខេត្ត ប្រាជីនបូរី តែពូជដែងរស្មីនេះមានដើមពូជនៅឯខេត្តត្រាត ។

ឆ្នាំ 2509 លោក ប៉ី ដែលធ្វើការនៅស្ថានីយពិសោធន៍រុក្ខជាតិចំការនៅបាងកកតូច ទៅតមែក 10 មែក ពូជនៅត្រាតរួចយកមកដាំ ហើយពង្រីកពូជតមក មហាឆិម បានទិញមកមួយមែកតម្លៃ 150 បាត ហើយបានបង្កើនពូជមកដាំនិងលក់ តែត្រូវទឹកលេច ដើមធំងាប់អស់ក្នុង ព.ស 2518-2519 សល់តែដើមតូចតែក៏មានអ្នកនាំយកទៅដាំ និងបញ្ចេញផលទៅមហាវិទ្យាល័យឈៀងម៉ៃដើមនោះឈ្មោះ " ខ្នុរពូជអ៊ុំដែង " សាច់ ក្លែបក្រាស់ស្រួយពណ៌ចំប៉ា ។

## ខ្នុរពូជខុនវិឆាន

ដើមពូជនៅជាប់ផ្ទះ ខុនប្រាក់យូនក្រុងថេប បានប្រគល់អោយលោក វិឆាន ជាប្រធានបច្ចេកទេសស្ថានីយពិសោធន៍រុក្ខជាតិចំការបាងកកតូច ក្នុងសម័យនោះជាអ្នកនាំមែកចេញលក់ ហើយផ្សព្វផ្សាយដល់ប្រជាជនរហូតទល់បានឈ្មោះថាខ្នុរខុនវិឆានតែអ្នកខ្លះហៅថា "ខុនវិឆាន" ខ្នុរនេះចង្អៀតបន្តិចត្រង់ទងជាងខ្លី មានក្លែបពណ៌ចំប៉ា សាច់ក្រាស់សមគួរតែសាច់មិនស្រួយ ។

ធ្លាប់សាកសួរអាចារ្យ ខ្លងឆៃ ប្រធានស្ថានីយវិច័យប៉ាកឆងដល់ខ្នុរពូជនេះដឹងថា មានភាពល្អលេចច្បាស់ល្មមប្រើ គឺក្លែបធំហើយក្រាស់ បច្ចុប្បន្ន ខ្នុរពូជនេះជាទិនិយម របស់ស្រុកប៉ាកឆង តែមនុស្សម្តុំនេះមិនហៅឈ្មោះថា " ខុនវិឆាន " ទេត្រឡប់ទៅហៅឈ្មោះថ្មីថា " ខ្នុរខុនរស្មី" ព្រោះបាន ដាំទុកឯផ្ទះរបស់ខុនរស្មី កាលពីច្រើនឆ្នាំមុនមក ទោះជាផ្លាស់ស្រុក ប៉ាកឆងក៏ ហៅជាប់មាត់ថា "ខ្នុរខុនស្មើ" របស់មនុស្សម្តុំនោះ ។

## ខ្នុរពូជចិកពុក

បានមកពីការបណ្តុះគ្រាប់ពីដើមខ្នុរដែលបានដាំ 30 ឆ្នាំមកហើយ ដើមពូជសាច់លឿង (បាត់ពូជទៅហើយ) ពេលនាំទៅដាំនៅស្រុក ប៉ាកថ បានដើមល្អចេញមកផ្លែធំបានយកមកប្រកួតបានលេខមួយ បានរង្វាន់ 200 បាតរោយចិកពុក " ម្ចាស់" ធ្លាប់អោះចិកញៀវម្នាក់ដែលស្គាល់ចិកពុកមកលួចជញ្ជូនទៅមិនរួចត្រូវចោលទៅក្នុងព្រៃស្មៅ ។ បច្ចុប្បន្នដុះនៅទីនោះធន់ទ្រាំនិងទឹកបានល្អបណ្តុះគ្រាប់ ហើយក្លាយពូជអស់ សាច់ក្រាស់ ស្រួយ ស្ងួត ព្លែបពណ៌លឿង រសជាតិល្អ ជ្រាំងលឿងសាច់សបន្តិច ទងវែងគ្រាប់មិនធំប៉ុន្មានទេ ទងផ្លែដូចស៊ុតច្រើនផ្លែជាចង្កោម សំបកខៀវលឿងពេលនៅខ្ចី តែពេលចាស់ទុំសំបកលឿងខៀវ ស្លឹកមិនម្ចលហើយមិនតូចល្អិត ។ ជាខ្នុរសាច់ក្រាស់ល្មមសមគួរ តែក្រាស់និងឆ្ងាញ់ទប់និងខ្នុរខាងប្រាជីនមិនបាន ។

## ខ្នុរភ្លូង ឬខ្នុរចង្កោម

"ចង្កោម" យ៉ាងតិចត្រូវមានផ្លែពីរ ចេញផ្លែពីទងតែមួយដោយហេតុនេះ ហើយចង្កោមមួយៗត្រូវមានយ៉ាងតិចពីរផ្លែឡើងទៅ ។ យើងឃើញខ្នុរចេញផ្លែពីទងតែមួយមានតាំងពីមួយទៅបួនផ្លែ តែចំពោះ " ខ្នុរចង្កោម" នោះមួយចង្កោមច្រើនមានផ្លែច្រើនជាងបួនផ្លែ ឡើងទៅគឺចង្កោមមួយៗមានប្រមាណ 5-10 ផ្លែ ពេលចេញផ្លែជាចង្កោមនរណាឃើញមិនបានគិតក៏ហៅថាខ្នុរចង្កោម ។

ខ្នុរចង្កោមផ្លែមិនធំ ហើយផ្លែនីមួយៗក្នុងចង្កោមមានខ្នាតមធ្យមប្រហាក់ប្រហែលគ្នាណាស់ ។ ខ្នាតរបស់ផ្លែទម្ងន់ប្រមាណ 2-4 គីឡូ ខ្នុរចង្កោមគួរចាប់អារម្មណ៍ថាសាច់ល្អ ផ្លែតូចរនែងរណោងផ្លែមួយៗបេះសាច់បានមួយចានបរិភោគម្នាក់អស់មិនពិបាកពុំមានបញ្ហាក្នុងការលក់ដូរ ។

លក្ខណៈខ្នុរចង្កោម ពេលបានទៅឃើញបរិភោគហើយសាកសួរសេចក្តីសរុបពីឈ្មោះគ្រូបាន់ផៅនិងដឹងថាលក្ខណៈដើមក៏មិនប្លែកពីខ្នុរណាំងទូទៅ ប៉ុន្មាន ចេញផ្លែជាចង្កោមៗប្រមាណ 4 - 10 ផ្លែទម្ងន់ប្រមាណ 2-4 គីឡូក្រាម លក្ខណៈផ្លែម្ចលដូចបាល់ បន្លាមិនវែងហើយមិនញីកពេក

សំបកមិនក្រាស់ តែក៏មិនស្តើងដូចខ្នុរល្អុត ពេលផ្លែចាស់អាចស៊ីបានសំបកមិនស្អិតពេកទេហែកចេញបានស្រួលជាងខ្នុរណាំងសំបកពុំសូវមានជ័រ សូម្បីតែពេលកាត់មកពីដើមថ្មីៗក៏ដោយ ហើយបើទុកចោលមួយយប់ពេលពុះចេញស្ទើរពុំមានជ័រ ឬមានជ័រតិចណាស់ បេះផ្លែបចេញពីសំបកនិងស្នូលបានស្រួល ជ្រាំងតិច ឬស្ទើរពុំមានជ្រាំងសោះ ។ សាច់ផ្លែបមានពណ៌ចំប៉ាសាច់ស្អិតស្រួយឆ្ងាញ់ ពេលចាស់លើដើមយកមកបានដោយមិនចាំបាច់បន្ទុំ តែរសជាតិផ្អែមលាយជូរតិចៗអ្នកចូលចិត្តបែបនេះទទួលមិនខុសចិត្តឡើយ ពេលបានបរិភោគខ្នុរចង្កោមតែបើយកមកបន្ទុំតែជំក្លិនរស់ជាតិផ្អែមបែបខ្នុរណាំងពណ៌ចំប៉ាទូទៅ ។ សាច់ផ្លែបគ្រាប់កាលណាធៀបនិងខ្នាតរបស់ផ្លែ គឺសមល្មមគ្នាល្អណាស់និងថាគាត់ស្តើងក៏មិនកើតព្រោះផ្លែខ្នាតប៉ុណ្ណឹង តែបើទៅប្រៀបធៀបនិងផ្លែខ្នុរណាំងធំៗក៏រាត់ផ្លែបរវែងទាប់ចុលមិនបានឡើយ ។

គ្រូប៉ាន់ថៅប្រាប់ថាដើមនិមួយៗធ្លាប់ផ្តល់ផ្លែបានប្រហែល 200 ផ្លែ និងរបេះពេលកាន់ផ្លែប្រមូលផលបានព្រមៗគ្នា និងខ្នុរណាំងទូទៅគឺ ផ្តើមបេះផ្លែ បានតាំងពីខែ កុម្ភៈ សីហា រាល់ឆ្នាំកាលពីខែសីហា ព.ស 2527 ខ្ញុំធ្លាប់យកខ្នុរចង្កោមពីចំការគ្រូ ប៉ាន់ថៅ មៅអោយអាចារ្យ ឱប្រម ភ្លក់មើល លោកប្រាប់ថាមានគុណសម្បត្តិមួយបែបទៀតដែលមិនគួរអោយស្អប់ ។

បុគ្គលិកដែលបាននាំខ្ញុំទៅមើលខ្នុរចង្កោម ឯចំការគ្រូប៉ាន់ថៅជាមនុស្សដំបូងគឺ " លោកសិងឆៃ" ខណៈនោះលោកជាអ្នកបច្ចេកទេស ការិយាល័យកសិកម្មខេត្តប្រាជីនបុរី បច្ចុប្បន្ននេះបានដឹងណឹងថា គ្រូប៉ាន់ថៅពង្រីកពូជទុកខ្លះហើយ ល្អមលក់អោយលោកដែលជាអ្នកចាប់អារម្មណ៍ ។

## ពូជស្រាលសំបកផ្អែម

" ខ្នុរពូជស្រាលសំបកផ្អែម" ជាខ្នុរណាំងមានឈ្មោះ ស្រុកលក់ម៉ៃ ដែលអាចារ្យ ឱប្រមនាំមកភ្ជាប់ពូជអោយស្គាល់ ។ ខ្នុរពូជស្រាលសំបកផ្អែម បានត្រូវហៅឈ្មោះតាមនេះតាំងពីគ្រានោះមក ខ្នុរពូជនេះមានពូជគួរអោយចាប់អារម្មណ៍ច្រើនយ៉ាងមិនថាលក្ខណៈផ្លែ ដែលមូល រសជាតិផ្អែម ផ្លែច្រើន ហើយចំណុចសំខាន់ៗគឺទាំងផ្លែបនិងជ្រាំងរហូតទៅដល់សំបកមានរសជាតិផ្អែមផ្លែមិនធំហើយមិនតូចពេក សូម្បីយើងមិនដែលបទូលទានសំបកខ្នុរទេ តែខ្នុរដែលអានសំបក

ផ្អែម ជ្រាំងផ្អែម និងក្លែបផ្អែមចាត់ជាខ្នុរលក្ខណៈពិសេសដែលគួរចង់តាមទៅមើលអោយឃើញច្បាស់ ។

ស្រុកលំភាត់ ជាស្រុកថ្មីក្រោយពីចែកញែកចេញពីស្រុក ឡាំងស្វន ស្រុកនេះជាសាខាស្រុកដែលតាំងនៅស្រុកលំភាត់ឆ្ងាយពីខេត្តប្រមាណ 80 គីឡូម៉ែត្រ ប្រជាកសិករក្នុងស្រុកប្រកបរបរអាជីពខាងការធ្វើចំការផ្លែឈើ ចំការកាហ្វេ និងចំការកៅស៊ូភាគច្រើន ។

ចំការខ្នុរដែលមានឈ្មោះនៅក្នុងរឿងខ្នុរពូជស្រាលសាំបកផ្អែម នោះជាចំការក្នុងខេត្តលំភាត់ ម្ចាស់ចំការឈ្មោះ ចាំរ័ត ឆ្ងាយពីស្រុក 3-4 គីឡូម៉ែត្រ ដោយផ្ទះរបស់លោកនៅត្រង់គីឡូលេខ 82 ចន្លោះស្រុកឡាំងស្វន និងស្រុកឡាក់ម៉ែនៅជាប់ចិញ្ចើមថ្នល់មានប៉ាយធំប្រាប់ថាជា ស្ថានីយ៍លក់ពូជខ្នុរ ។

ប្រមាណឆ្នាំ ព.ស 2500 លោកមានភូមិកំណើតនៅកោះសមុយ បានធ្វើដំណើរមករកកន្លែងថ្មីបានទិញដីមួយកន្លែង ហើយដីនោះមានខ្នុរមួយដើម ដឹងថាមានអាយុប្រមាណ 8 ខែ ខ្នុរដើមនោះជាខ្នុរដែលគេយកមកពីខេត្តផ្សេងៗមិនច្បាស់ ពេលនាំមកក៏ប្រាប់ថាជាខ្នុរពូជល្អ ហើយចែកចាយគ្រាប់ខ្នុរចំនួនបីគ្រាប់អោយអ្នកភូមិបីនាក់យកទៅដាំ ។ តែខ្នុរដែលនាំទៅដាំបានរស់តែមួយដើមខ្នុរដែលលោកល្បួនយកមកដាំចំការរបស់លោកសិទ្ធ ។ តមកកន្លែងនោះបានចែកលក់អោយលោកចាំរ័ត ខណៈនោះខ្នុរដើមនេះមានអាយុ 8 ខែហើយ ។

លុះដឹងថាខ្នុរដើមនោះជាខ្នុរពូជល្អ លោកបានយកចិត្តទុកដាក់ជាពិសេសអាយុប្រមាណពីរឆ្នាំកន្លះខ្នុរទើបចាប់អោយផ្លែ ពេលខ្នុរនោះទុំបាននាំមកពុះមើលឃើញថាគ្មានជ័រ ហើយខាងក្នុងមានពណ៌លឿងលាយក្រហម មិនថាក្លែបជ្រាំង រហូតដល់សាំបក ។ បានពិសោធន៍ភ្លក់គ្រប់ផ្នែកឃើញថាអាចទទួលទានបានទាំងអស់ ក្រោយពីនោះឆ្នាំតមកលោកចាប់ផ្តើមពង្រីកពូជដោយនាំគ្រាប់ខ្នុរដើមពូជចំនួនពីរផ្លែមកពង្រីកពូជមានចំនួនប្រមាណ 300 ដើម ដោយដាំនៅកន្លែងដដែល តមកគេបានសង់ផ្លូវកាត់ដីលោកខ្នុរត្រូវនៅប្រមាណ 70 ដើម ។

ខ្នុរដែលដាំទុកដោយគ្រាប់អាយុប្រមាណពីរឆ្នាំកន្លះ ក៏ផ្តើមផ្តល់ផលប្រមាណ 10 ដើមលុះអាយុប្រមាណ 4 ឆ្នាំ ខ្នុរផ្តល់ផលទាំងអស់ តែមានខ្នុរដែលនៅរក្សាគុណសម្បត្តិត្រឹមតែ 4 ដើមប៉ុណ្ណោះ ហើយក្រៅពី 4 ដើមលោកបានចាប់ផ្តើមបណ្តុះពូជដោយគ្រាប់ចេញលក់តាមរបៀបផ្សេងៗមកប្រមាណ 10 ឆ្នាំឃើញថាមនុស្សដែលចង់បានខ្នុរល្អខ្លះមិនបានល្អខ្លះណាយគ្នា សម័យនោះលោកបានសិក្សាទាក់ទងបច្ចេកទេសតមែក មកទើបចាប់ផ្តើមតមែកខ្នុរកេញលក់ពីបួនដើមមុនដើម្បីតមែកដាំជាដើមមេពូជចំនួន 60 ដើម ហើយបានតមែកលក់មកដល់បច្ចុប្បន្ន ។

ខ្នុរដែលបានរៀបរាប់ប្រវត្តិមក និងអនុញ្ញាតិអោយអ្នកជិតខាងបានពិសោធន៍ភ្លក់មើលដំបូងបានដាក់ឈ្មោះឡើងដោយប្រកាន់យកលក្ខណៈដែលជាខ្នុរស្រាល ហើយគ្រប់ផ្នែកអាចទទួលទានបានទើបហៅឈ្មោះនៅក្នុងពេលនោះថាខ្នុរពូជស្រាលសំបកផ្អែម ហើយបានស្គាល់ក្នុងរង្វង់អ្នកដាំខ្នុរទូទៅ ។ តមកខាងការិយាល័យកសិកម្មខេត្តបានសុំអោយប្តូរឈ្មោះពីខ្នុរ “ពូជស្រាលសំបកផ្អែម” មកជាពូជស្រាលលក់ម៉ៃ ដើម្បីអោយកើតប្រវត្តិរបស់ស្រុកដែលជាចំណុចផ្តើមដែលមានអាយុច្រើនជាង 30 ឆ្នាំ ក៏មាននៅកន្លែងដើមគ្រាន់តែទ្រុឌទ្រោមទៅតាមកាលវេលានិងអាយុប៉ុណ្ណោះ ។

ដូចបានរៀបរាប់ ហើយលំដាប់ផ្តើមដំបូងការបន្តពូជខ្នុរនេះបានផ្តើមមកពីគ្រាប់ ហើយមានខ្នុរដែលនៅរក្សាលក្ខណៈដើមត្រឹមតែបួនដើម ខ្នុរទាំងបួនដើមនោះអោយឈ្មោះថាខ្នុរពូជស្រាលលក់ម៉ៃដូចគ្នា តែចំពោះបួនដើមនេះផ្អែមនិងមានរសជាតិដូចគ្នា ចំណែកផ្លែមានលក្ខណៈវែងដើមខ្លះមានផ្លែមូលដើមខ្លះពុំមានបន្លា មានត្រឹមតែបន្តិចបន្តួច ដើមខ្លះផ្លែធំ ហើយមានបន្លាមានត្រឹមតែបន្តិចបន្តួច បើមិនមានបន្លានោះលោកបានអោយយោបល់ថាខ្នុរបួន ដើមនោះបែងបានជាពីរពួក គឺពួកស្លឹកល្អិត និងពួកស្លឹកធំ ពួកស្លឹកល្អិតនៅរក្សាលក្ខណៈផ្លែ ស្រវេឿងនិងផ្លែមច្រើន ខណៈដែលខ្នុរពួកស្លឹកធំមានលក្ខណៈផ្លែបែកគ្នាពីដើមមេខ្នុរពីដើមមេដែលសំបកផ្លែមានបន្លាបន្តិចបន្តួចចុងបន្លាស្រួចមានផ្លែមូលស្រវេឿងពាល់ទាត់ ។

## ខ្នុរមិនមានជ័រ

ធូរេនមិនមានបន្លា ខ្នុរមិនមានជ័រ ដោយខ្សែពូជហើយមិនគួរនិងមាន គឺធូរេន បើមិនមានបន្លា វាមិនគួរហៅថាធូរេន ហើយខ្នុរបើមិនមានជ័រក៏មិនគួរហៅខ្នុរ តែចំពោះធូរេននោះគេធ្វើអោយវាមិនមានបន្លាបានហើយដោយការកាច់បន្លាចេញពាំងពីផ្លែខ្ចីៗ ចំណែកខ្នុរមិនមានជ័រនៅមិនទាន់ធ្លាប់ ឃើញផ្ទាល់និងភ្នែកខ្លួនឯង ។ ត្រឹមតែនិយាយអោយគេស្តាប់ខុនលប៉ិងលៃបធ្លាប់នាំទៅមើលចំការអ្នកផាន់ថងជាំ ហើយយើងយល់ថាគ្មានជ័រសោះ ក៏ពិបាកនិយាយព្រោះពិតៗ ហើយមានជ័រមិនតិចតែជ័រមិនស្អិតខ្លាំង ហើយពេលទុកចោលប្រមាណ 4-5 ម៉ោងជ័រនិងហួរចេញតិច ។

ពិតមែនហើយខ្នុរមិនមានជ័រ តែគួរជឿថាខ្នុរតែងតែមានជ័រមួយ ពូជខ្នុរដែលនិយាយមកទាំងនោះជាពូជខ្នុរដែលបានជ្រើសរើសអោក
ហើយព្រមទទួលច្រើនអ្នកថាជាពូជខ្នុរដែលមានគុណសម្បត្តិ តែមួយ ពោលគឺពូជល្អដែរតែមិនមែនជាពូជដែលល្អបំផុត រកពូជផ្សេងធៀបមិនបាននោះទេ ។ តែកាលណាស្វែងតាប់អារម្មណ៍ ជ្រើសរកពូជល្អពីកន្លែងផ្សេងៗ យើងនឹងទទួលបានថាត្រូវមានពូជខ្នុរថ្មីៗទៀតច្រើនមិនចាញ់ពូជស្វាយពូជធូរេនឡើយ ព្រោះខ្នុរដែលដាំពីគ្រាប់នោះពាំងឈ្មោះថ្មីស្ទើរបានគ្រប់ដើមរណ្តាលពីក្លាយពូជភាគច្រើនលើកលែងដូចដើមមេប្រាកដប៉ុណ្ណោះ តែឱកាសនេះតិចណាស់ ។

សេចក្តីពិចារណាជ្រើសរើសពូជខ្នុរក្នុងភូមិស្រុក យើងនៅប្រកាន់គោលការប្រកួតទាំងអស់មិនបានព្រោះការប្រកួតមិនអាចគ្រប់ដណ្តប់បានសព្វ ដូច្នោះដើមពូជជ្រើសរើសដែលល្អ ក្រៅពីបញ្ហាផ្សេងខាងរស់ជាតិគុណភាពផ្លែ ហើយផ្លែច្រើនរបស់ដើមនោះៗជារឿងសំខាន់ណាស់ បើបានជ្រើសរើសពូជដែលមានអាយុរវាង 7 - 10 ឆ្នាំបានរឹតតែល្អ ។ ក្រៅពីអាយុ 7 ឆ្នាំឡើងទៅយើងអាចនិយាយថាផ្តល់ផ្លែបានពេញទីក្នុងមួយដើម ហើយក្នុងមួយឆ្នាំ គួរបាន 25 ផ្លែ ក្នុងមួយដើមយ៉ាងតិច ហើយផ្លែនីមួយៗមានទម្ងន់បញ្ឈមមិនទាបជាង 7 គីឡូក្រាម ។ ដើមខ្លះអោយផលតែម្តងតែដើមខ្លះផ្តល់ផលពីរដងក្នុងមួយឆ្នាំៗ គួរជ្រើសរើសដើមដែលផ្តល់ផលតាមគល់ ឬមែកធំៗ ។ ដើមខ្លះអោយផលតាមមែកលើៗនោះផ្លែមិនសូវល្អ ហើយផ្លែទាំងនោះតូចៗ ។ ដើមដែលចេញផ្លែតាមគល់ និងមែកធំៗអ្នកដកផលការប្រកួតនោះគេមិនបានផ្តោតជល់

រឿងនេះ ហើយគណៈកម្មាធិការសំរេចចិត្តដោយមិនបានជ្រាបថាខ្នុរដែលសំរេចអោយរង្វាន់ទីមួយពិតៗនោះផ្លែច្រើន ឬអត់ជានាទីដែលពួកគេគួរគិតពិចារណាជ្រើសរើស ។ តាមដែលសង្កេតមកឃើញខ្នុរពូជល្អៗក្នុងក្រុមខ្នុរណាំង សាច់ក្លែប ពណ៌លឿងនោះច្រើនមានស្លឹកធំ ហើយស្លឹកច្រើនរលីង ស្លឹករលើប ទ្រនុងស្លឹក លេចច្បាស់ ស្លឹករាងបូលអេឡិក ពណ៌ខៀវចាស់ ស្លឹកក្រាស់ ដើមពុំសូវរលីង បែកមែកធាងសាខាគ្មានរបៀប មានផ្លែមូល មូលកណ្ដុប ហើយវែង បន្លាធំ ហើយឃ្លាតពីគ្នានៅពេលចាស់ ។

ចំណែកខ្នុរពូជល្អក្នុងក្រុមខ្នុរណាំង សាច់ក្លែបពណ៌ចំប៉ា ច្រើនមានស្លឹកតូចជាងស្លឹកខ្លោបបន្តិច ទ្រនុងស្លឹកមិនច្បាស់ស្នាលសសៃ ស្លឹកមិន មានរបៀប ស្លឹកវែង ចុងស្លឹកស្រួច ដើមខ្លះស្លឹកក្រាស់ដៃ តែដើមខ្លះស្លឹករអិលមិនក្រាស់ដៃក៏មានខ្លះដូចគ្នា សំបកដើមរលីងជាងខ្នុរណាំងសាច់លឿង ដើមរាងខ្ពស់មិនសូវបែកមែកទៅខាងរាងផ្លែទូទៅមូលវែង ផ្លែមិនសូវមានច្រើនទេ លើកលែង តែខ្នុរចង្កោមបន្លាផ្លែល្អិត ហើយញឹកជាងបន្លាក្នុងខ្នុរពណ៌លឿងស្នាលខ្នុរនោះធំឬតូច បើទងផ្លែតូចខ្នុរនោះនិងមានស្នាលតូចតាមហ្នឹង ក្លែប រមែងវែងជាងផ្លែដែលមានស្នាលធំជាង ។ ចំណុចអង្កេតទាំងនេះមិនមែនត្រឹមត្រូវណាស់ណាទេ គ្រាន់តែជាការសង្កេតពីការប៉ិនប្រសប់ប៉ុណ្ណោះ ។

រាងផ្លែមូលឬវែងបន្តិច ពណ៌សំបកផ្លែលឿងខ្ចីមានបន្លារយាលបន្លាមិនខ្ចី ឬវែងពេក សំបកក្រាស់មធ្យម ទងផ្លែតូច ស្នាលផ្លែមិនធំ សាច់ក្លែបធំ ហើយក្រាស់ស្រួយរសជាតិផ្អែមក្រអូបក្លិនជាប់ច្រមុះ (ពេលបរិភោគ) សាច់មិនជ្រាយហើយស្វិត ជ្រាំងតិចក្លែប ច្រើន គ្រាប់តិច ពណ៌ក្លែបលឿងឬ ចំប៉ាតែមានខ្នុរពណ៌លឿងចាស់ស្ទើរក្លាយទៅជាពណ៌ចំប៉ាក៏មានសាច់ក្លែបពណ៌ស្រស់ ចុងក្លែបដែលជាប់និងសំបកមិនបត់ង ហើយទងក្លែបដែលជាប់និងស្នាលតែពាក់កណ្ដាលមិនពេញមុខក្លែប ។

ការពិតហើយពណ៌ក្លែបខ្នុរនោះគ្រាន់តែទាញមករាងយឺតវែងពេលបរិភោគ ព្រោះមានខ្នុរដើមខ្លះដែលមានពណ៌សាច់ក្លែបសមិនមានពណ៌ផ្សេងៗលាយសោះ តែជាទូទៅពណ៌របស់ក្លែបនិងចេញទៅជាពណ៌លឿង ហើយនិងចេញពណ៌លឿងខ្ចី ឬចាស់ដែលប្លែកផ្សេងគ្នា ។

លក្ខណៈផ្លែខ្នុរដែលរាងមានផ្លែមូលវែង ច្រើនមានខ្នាតក្លែបវែង ហើយខ្នាតក្លែបប្រហាក់ប្រហែលគ្នាទាំងមួយផ្លែ ដោយស្នូលមានខ្នាតដូចគ្នា ចំណែករាងផ្លែមូលច្រើនមានស្នូលកោងត្រង់កណ្តាលតែអាស្រ័យលើពូជនិងការកាន់ផ្លែផង ។

# 5. ការពង្រីកពូជខ្នុរ

តាំងពីដើមមក ការពង្រីកពូជឈើហូបផ្លែនិយមដាំដោយគ្រាប់ទើបក្លាយទៅជាពូជខ្នុរថ្មីៗទៀត សូម្បីមិនបានដាក់ឈ្មោះពូជថ្មីក៏ដោយ ហេតុនេះយើងត្រូវការជ្រើសរើសដើមពូជខ្នុរដែលមានគុណភាពល្អបានច្រើនពូជដូចបានពោលរួចមក ហើយក្នុងប្រភេទពូជតែខ្សែពូជក្រៅអំពីបានរៀបរាប់ហើយ យល់ថានៅមានពូជខ្នុរផ្សេងៗល្អទៀតច្រើន ។ ដូច្នេះបើយើងជ្រើសរើសដើមពូជល្អបាន ហើយត្រូវពង្រីកពូជពីដើមនោះទៅដាំតទៅ ដោយវិធីការពង្រីកពូជបែបផ្សេងដែលមិនមែនការបណ្ដុះផ្សាំអាចជាវិធីសាកមែក ភ្ជាប់ខាង តភ្នែក ឬប្ដូរត្រួយក៏បាន ។

## 1. ការសាកមែកខ្នុរ

ក្រាក់យ៉ាផេតផុងសាវិសុទ្ធថាធិបតី សរសេរទុកក្នុងសៀវភៅកសិករឆ្នាំទី 35 ក្បាលទី 6 ថាការ ការដាំខ្នុរដោយមែកសាកក្នុងក្រុងថេប កាលពីប្រមាណ ព.ស 2450 ដោយអ្នកធ្វើការសាកដាំបានទទួលផលល្អ ទើបនិយមសាកដាំខេត្តផ្សេងៗនៅប្រើដាំដោយគ្រាប់ ។ ក្រៅពីនេះលោកថា ឈើផ្លែដែលដាំពីមែកសាកច្រើនផ្ដល់សាច់ក្រាស់ ដូចជាធូរេន សាកល្អជាងធូរេនដាំពីគ្រាប់ ។ ល្មុតនិងពុទ្រាក៏ដូចគ្នាដោយផ្ដល់ហេតុផលថាទឹកចិញ្ចឹមដើមដើរពុំស្រួល (លោកបរាយហេតុផលត្រឹមតែប៉ុណ្ណោះ) តែមនុស្សច្រើនយល់ស្របនិងលោកថាការដាំមែកសាកច្រើនធ្វើអោយមានសាច់ច្រើន ហើយគ្រាប់តិចចុះ (តុហក ឬពិតយ៉ាងណាក៏មិនដឹងជាការសង្កេតប៉ុណ្ណោះ) ។

ការសាកមែកខ្នុរបានផលប្រមាណ 40-70% នៅរដូវដែលសមស្របចំពោះការសាកមែកគឺដើមរដូវភ្លៀង បើភ្លៀងមិនធ្លាក់គួរជួយស្រោចទឹក ត្រូវជ្រើសរើសសាកពីមែករំពង់ ឬមែកដែលមិនខ្ចី ឬចាស់ពេក (ករណីដែលជារំពង់អាចធំខ្នាតប៉ុនមេដៃក៏សាកបាន) ការឆ្វៀលមែកដើម្បីលកសំបកចេញគួរមានមុខប្រវែង 3-5 សង្ទីម៉ែត្រ លុះឆ្វៀលសំបកចេញ ហើយប្រើកាំបិតកោសសាច់ឈើស្រាលៗអោយរំអិលស្អិតៗ ឬកោសិកាដែលនៅជុំវិញស្នាមមុខឆ្វៀលចេញអោយអស់ ហើយទុកចោលប្រហែល 1 - 2 ថ្ងៃ ដើម្បីអោយជ័រ ដែលមាននៅហូរចេញអោយអស់ទើប

ធ្វើការរុំមុខផ្សៀលមែកសាករុំមែកសាករួច ហើយប្រហែល 45-60 ថ្ងៃ ទើបចេញឫស ។ មុនកាត់មែកទៅផ្សាំត្រូវសង្កេតមើលការដុះឫស គឺត្រូវមានឫសច្រើន ឫសប្រវែង 5-10 ស៊ង់ទៅ ហើយមានពណ៌លឿងចាស់ទើប កាត់យកទៅផ្សាំ បើពេលកាត់ឫសនៅខ្ចី (ឫសពណ៌ស) ច្រើនងាយងាប់ ។

ទោះបីការសាកមែកខ្នុរមិនមែនជាទីនិយមនាពេលបច្ចុប្បន្នតែមានការចាំបាច់ដែល និងត្រូវសាកដាំ ឬអ្នកណាដែលនៅជឿថាការដាំដោយមែកសាកនោះធ្វើអោយសាច់ក្រាស់ឡើង ហើយធ្វើអោយមានគ្រាប់តិចចុះចាំបាច់ត្រូវពិសោធនិដាំពីមែកសាកនោះ ។

2. ការដាំដោយគ្រាប់

ការបន្តពូជខ្នុរងាយបំផុតដោយការដាំគ្រាប់ ដោយគ្រាប់ពុំមានពេលសំរាកពោលគឺផ្លែខ្នុរដែលចាស់ ពេលកេះផ្លែបយកគ្រាប់ចេញអាចយកគ្រាប់ទៅបណ្ដុះបាន ឬទោះបីខ្នុរខ្លះគ្រាប់ដុះតាំងពីនៅក្នុងផ្លែក៏ដោយគ្រាប់ខ្នុរខ្នាតធំ ទើបមានអាហារប្រមូលក្នុងគ្រាប់ច្រើនពេលដុះជាដើមខ្ចីទើបចិញ្ចឹមដើមខ្ចីអោយលូតលាស់បានលឿន ។

ការពង្រីកពូជដោយភ្ជាប់មែកភ្ជាប់ភ្នែក ឬសៀតត្រួយត្រូវដាំដើមតពីគ្រាប់សិន ។ ដុះបានដើមតដែលមានខ្នាតសមល្មម ហើយទើបនាំដើមតទៅភ្ជាប់មែកពូជល្អដោយភ្ជាប់ពេញទុកលើដើមតឬមួយករណីទៀតគឺយកត្រួយមែកពូជដែលយើងត្រូវការមកសៀតលើ ដើមតទាំងនេះសុទ្ធតែត្រូវប្រើដើមដែលបានមកពីការបណ្ដុះគ្រាប់ទាំងអស់ ។ ពីដើមមនុស្សបុរាណជឿថាការនាំយកគ្រាប់ខ្នុរទាំងផ្លែប (មិនបេះយកសាច់ចេញ) ទៅបណ្ដុះច្រើនបានត្រូវតាមពូជ ដូចគ្នានិងការបណ្ដុះឈើផ្លែផ្សេងៗដាក់ទៅទាំងផ្លែតែការពិត ជំនឿនេះមិនបានជាការពិតទេព្រោះតាមគោលការណ៍បច្ចេកទេសកាលណាដាំអំពីគ្រាប់រមែងក្លាយជាពូជ ។

ការបណ្ដុះគ្រាប់ត្រូវយកគ្រាប់ពីផ្លែខ្នុរ ។ ដែលចាស់បេះយកតែគ្រាប់ទៅត្រាំទឹកមួយយប់ ហើយយកទៅបណ្ដុះ ។ ត្រូវបណ្ដុះក្នុងដីធូរដែលមានវត្ថុសរីរាង្គគ្រប់គ្រាន់ លុះអាយុដើម បាន

3-8 ខែ ឬដើមដែលមានស្លឹកពិតយ៉ាងតិច 3-5 សន្លឹក ក៏ប្រើជាដើមតដើម្បីភ្ជាប់ភ្នែក បានតែបើដើមតភ្ជាប់ភ្នែកនិងប្តូរត្រួយត្រូវមានអាយុ 8-12 ខែ ឬដើមមានបន្ទាត់ផ្ចិតប៉ុនខ្មៅដៃយ៉ាងតូច ។

## 3. ការភ្ជាប់ភ្នែក

ការភ្ជាប់មែកត្រូវមានដើមតបានពីការបណ្តុះគ្រាប់ ។ ដូចពោលហើយក្នុងចំណុចទីពីរអាយុដើមមិនត្រូវលើសពី 8 ខែ ព្រោះអាយុច្រើនពេកដកដើមតឫសដាច់ច្រើន ។ ការតមែកខ្នុរអាចនិយាយបានថាដំណាក់ការភ្ជាប់មិនខុសគ្នាពីការភ្ជាប់មែកស្វាយទេ ។ តែយ៉ាងណាចំពោះតែខ្នុរពេលចិតមែកច្រើនមានជ័រហូរចេញមកចាំបាច់ត្រូវចិតជ័រចេញមុនសិន ។ មុននិងយកទៅចូលតគ្នានិងមែកពូជល្អ ។

មែកពូជល្អដែលមានអាយុក្នុងរដូវអាចភ្ជាប់បានមែកច្រើនកន្លែង ។ ពោលគឺមែកពូជល្អដែលមានអាយុមែក 6-12 ខែល្អតលាស់ល្អលក្ខណៈជាមែកវែងមានស្លឹកច្រើន យើងអាចប្រើដើមតភ្ជាប់មែកក្នុងកន្លែងពីរប្រឡោះស្លឹកហើយបើមែកនោះវែង 10 ប្រឡោះ ស្លឹក យើងអាចភ្ជាប់បាន 5 កន្លែងក្នុងមែកនោះ ដោយធ្វើការភ្ជាប់ពីរប្រឡោះឆ្លាស់គ្នា ហើយប្រើឈើចងដោតឃិតដើមតនិងមែក ពូជល្អគ្រប់កន្លែងដែលធ្វើការភ្ជាប់ លុះអាយុកាលភ្ជាប់ បាន 35-45 ថ្ងៃ សាច់ឈើកន្លែងភ្ជាប់ និងផ្សាភ្ជាប់គ្នាល្អ ហើយក៏កាត់ចុះមកផ្សាំបាន ។

បើលោកភ្ជាប់ច្រើនកន្លែងក្នុងមែកជាមួយគ្នា ។ ត្រូវកាត់ដើមដែលនៅចុងយកមកផ្សាំមុន ហើយបណ្តាក់កាត់ស្នាមក្រោមស្នាមភ្ជាប់កន្លែងបន្ទាប់ចុះមក ករណីមែកភ្ជាប់ដែលនៅបន្ទាប់ចុះមកមានស្លឹកច្រើនល្មម ឬមានមែកខ្នែងបែកចេញមានស្លឹកចាស់ ហើយអោយកាត់ចុះមកព្រមនិងមែកភ្ជាប់ផ្នែកចុងបាន តែបើមែកដែលនៅបន្ទាប់ចុះមកមានស្លឹកតិចពេក ហើយពេលលាស់ភ្នែកខាងជាស្លឹកខ្ចី កុំទាន់កាត់យកត្រូវទុកទំរាំលាស់ត្រួយថ្មីទុកអោយស្លឹកចាស់ទើបចាំកាត់យក ។

ដើមខ្នុរដែលកាត់ចុះមកផ្សាំ (ពីការភ្ជាប់មែក) រវាងពេលផ្សាំអោយដើមរឹងមាំនោះច្រើនមាន ជំងឺផ្សិតមកបំផ្លាញគួរបាញ់ថ្នាំការពារ កំចាត់ជំងឺផ្សិតភ្លាមមុននិងផ្សាំដាក់ថង់ និងដីដែលប្រើផ្សាំដាក់ថង់ ឬកន្លែងជាដីដែលធ្វូរអាចទឹកចេញចូលស្រួលកាលណាស្រោចទឹកមិនដក់នៅ ។

## 4. ការភ្ជាប់ភ្នែក

ក្រៅពីការភ្ជាប់មែកហើយខ្នុរនៅភ្ជាប់ភ្នែកបានមិនពិបាកពេកទេ ។ មនុស្សច្រើនដែលចូលចិត្តមែកពូជពីការភ្ជាប់ភ្នែក ទើបនិយមវិធីនេះ ។ ការភ្ជាប់ភ្នែកខ្នុរក៏មិនខុសផ្លែកពីស្វាយដែរ តែដើមតត្រូវមានខ្នាតធំបន្តិច ។ ហើយគួរចិញ្ចឹមដើមទុកអោយរឹងមាំសិន ភ្នែកដែលនាំមកភ្ជាប់ត្រូវជាភ្នែកមែកពូជល្អអាចលកយកសាច់ចេញពីសំបកបានស្រួល ។

## 5. ការប្តូរត្រួយ

ដោយខ្នុរចេញផ្លែតាមគល់ ឬមែកធំ ដូច្នេះការប្តូរត្រួយធ្វើក្នុងពាំដារ់ដើមគល់ ។ ហើយត្រូវធ្វើនិងដើមតឬដើមខ្នុរដែលត្រូវការប្តូរត្រួយមានអាយុមិនអោយលើសពី 2-3 ឆ្នាំ ហើយត្រូវប្តូរត្រួយក្នុងកន្លែងដែលនៅជិតបំផុត ។ បើបណ្តោយអោយផ្នែកគល់តខ្ពស់ពេក ពេលដើមអាយុច្រើនផ្នែកគល់ដើមជាដើមត (មិនមែនផ្នែកដើមពូជអោយផ្កាកាន់ផ្លែ) មិនត្រូវការវិធីការប្តូរត្រួយធ្វើបានពីរលក្ខណៈដូចគ្នានិងការប្តូរត្រួយស្វាយទេ គឺការប្តូរត្រួយសៀតខាងនិងបើកសៀតសំបក តែទាំងពីរវិធីនេះត្រូវប្រើត្រួយពូជដែលនៅខ្ចី និងភ្ជាប់បានល្អជាងប្រើត្រួយពូជល្អពីមែកដែលចាស់ឬមែកល្អចុងតូចៗមិនមែនត្រួយ ទោះជាយ៉ាងណាក៏ដោយផ្នែកករបស់មែកពូជល្អដែលនិងយកមកតត្រួយ ។ ប្តូរត្រួយអាចមិនចាំបាច់ត្រូវប្រើមែកត្រួយជានិច្ចក៏បាន ។

វិធីការប្តូរត្រួយនិងការភ្ជាប់ភ្នែកនោះ ត្រូវធ្វើក្នុងកន្លែងដាំដោយផ្ទាល់ គឺធ្វើការដាំដើមតចុះទៅក្នុងកន្លែងដាំតែម្តងប្រើចន្លោះការដាំដើមតយកតែម្តង លុះចិញ្ចឹមដើមតក្នុងកន្លែងដាំបានមួយឆ្នាំ ហើយឬមិនលើសពីរឆ្នាំទើបធ្វើការភ្ជាប់ភ្នែក ឬ ប្តូរត្រួយតាមពូជដែលយើងត្រូវការបាន ។

គោលការណ៍ភ្ជាប់ភ្នែកឬប្តូរត្រួយ ច្រើនដុះភ្នែកខាងដើមត ក្រោមពីកន្លែងភ្ជាប់ភ្នែកឬកន្លែងតត្រួយដូចនោះត្រូវខំសង្កេតហើយធ្វើការក្តិចភ្នែកខាងដែលលាស់ពីដើមតចេញ បើពុំដូច្នោះទេភ្នែកដើមខាងរបស់ដើមតនិងដណ្តើមគ្នាដុះជាមួយភ្នែក ឬមែកពូជល្អ បើទុកអោយមានភ្នែកខាងហើយភ្នែកខាងដើមរបស់ដើមតដុះតទៅនិងមានផលធ្វើអោយភ្នែក ឬមែកត្រួយរបស់ពូជផ្អាកការលូតលាស់ ហើយងាប់ទៅក្នុងទីបំផុតត្រូវប្រយ័ត្នរឿងនេះ ។

លោកដែលត្រូវការដាំខ្នុរប្លុកធំៗ ឬដាំចំនួនច្រើនដើមត្រូវដាំដើមតនៅកន្លែងដែលដាំយកតែម្តងមុនសិន ហើយមកភ្ជាប់ភ្នែក ឬប្តូរត្រួយក្នុងពេលក្រោយល្អជាងយកមែកទៅដាំ ព្រោះដើមតស្ថាបនាប្រព័ន្ធឫសបានល្អជាងមែកដែលភ្ជាប់នាំមកបំបែកដាំពេលក្រោយ ។ តែលោកត្រូវមានមនុស្សពង្រីកពូជផង របៀបភ្ជាប់ភ្នែក ឬប្តូរត្រួយអាចខ្លួនលោកផ្ទាល់ជាអ្នកធ្វើក៏បានគឺលោកប្តូរត្រួយស្វាយបានផលមក ហើយរមែងធ្វើអ្វីមិនពិបាកគ្រាន់តែប្តូរត្រួយខ្នុរ ។

ដើមមេពូជ

គឺដើមពូជដែលយើងត្រូវការពង្រីកមកដាំ អាចជាខ្នុរពូជតាបួយ ហ្វេថាឡុម ចំប៉ាក្រប ដែងរស្មី ឬពូជណាមួយក៏បានស្រេចទៅលើ លោកគិតថាជាពូជល្អដូចបានរៀបរាប់មកហើយ ។ ដំណាក់ការដំបូងត្រូវការជ្រើសរើសដើម មេពូជនោះជាដើមដែលមានអាយុមិនទាប ជាង 7 ឆ្នាំឡើងទៅ ។ កាលណាធ្វើការភ្ជាប់មែកធ្វើដោយពិបាកបន្តិចព្រោះដើមធំ ហើយជួនកាលរកមែកដែលល្អសមស្របពិបាកណាស់ ។ ត្រូវធ្វើការពង្រីកពូជពីដើមមេពូជចុះមកដាំ ហើយការពង្រីកពូជដើមនេះទៀត វានិងស្រួលជាងព្រោះដើមមិនខ្ពស់ ហើយបែកមែកថ្មីដែលសមស្រប ដើម្បីធ្វើការភ្ជាប់មែកបានច្រើនជាងដើមធំ ។

សន្មត់ថាលោកបានដើមខ្នុរពូជល្អខ្ពស់ខ្នាតពីរហ្វូត មកមួយដើមលោកត្រូវនាំយកដើមនោះទៅដាំ ហើយចិញ្ចឹមថែរក្សាអោយបានល្អត្រឹម អាយុដាំចុះដីបាន 5-6 ខែ លោកក៏អាចពង្រីកពូជបានពីខ្នុរដើមនេះទៅបានយ៉ាងច្រើន ព្រោះខ្នុរវាតែកាត់មែកពេលនោះវាបែកមែកថ្មីបានច្រើន ហើយមែកថ្មីដែលបែកចេញមកជាមែកដែលស្របនិងការភ្ជាប់មែកក្នុងគ្រាតទៅ ។

អ្នកចំការត្រូវសន្សំលុយចំណែកនេះទុកដោយការរកទិញមែកពូជល្អមកត្រឹមតែ 2-3 ដើម ហើយមកពង្រីកខ្លួនឯងក្នុងចំការមិនចំណាយលុយទិញមែកពូជគេមិនបាច់ដាំតែម្តងច្រើនឡើយ ព្រោះខាតលុយទទេៗ ព្យាយាមហ្វឹកហាត់ការពង្រីកពូជអោយកើតហើយលោកនិងសន្សំប្រាក់ទិញមែកពូជបានច្រើនសូម្បីមានផ្លែឈើពូជថ្មីៗចេញមករឿយៗ លោកក៏ពង្រីកពូជបានលោកនិងបានចាប់អារម្មណ៍លើពូជឈើផ្លែនោះដោយហ្វឹកហាត់ដោយខ្លួនឯងពីសៀវភៅ " ពង្រីកពូជឈើផ្លែ " ដែលជាច្បាប់ពិសេសលំដាប់ទី 4 របស់កសិកម្មរកទិញទៅអាន ហើយមើលរូបភាពរូមផ្សំផងអំពីរបៀបការពង្រីកពូជសៀវភៅពង្រីកពូជឈើផ្លែ ក្បាលនេះមានវិធីការពង្រីកពូជឈើផ្លែប្រភេទច្រើនច្រើនបែប ច្រើនវិធីការផ្សេងៗល្អមនិងលោកដែលហ្វឹកហាត់ដោយខ្លួនឯងបាន ព្រោះមានរូបភាពរូមផ្សំដំណាក់ការធ្វើច្រើន តម្លៃមួយក្បាល 38 បាត ប៉ុណ្ណោះតែលោកអាចពង្រីកពូជឈើបាន 3-4 ដើមក៏រួចថ្លៃសៀវភៅហើយ ។

# 6. ការដាំដំណាំខ្នុរក្នុងចំការ

មុនពេលលោកគិតដាំដើមខ្នុរយ៉ាងតិចបំផុតលោកត្រូវដាក់ផែនការទុកមុនថា ដាំខ្នុរដោយមានបំណងរបៀបណា និងដាំចំនួនប៉ុន្មានដើម ដាំនៅកន្លែងណា ដាំទុកមើលលេងឬធ្វើអ្វីលោកត្រូវដាក់ផែនការមុនសិន ។

## 1. ដាំលើព្រំដី ឬជារបងជុំវិញចំការ

ចំការទំនាបមិនថាចំការឈើផ្លែអ្វីក៏ដោយ ត្រូវលើកភ្លឺដើម្បីការពារទឹកលិចជានិច្ច ។ ហើយបើភ្លឺនោះនៅមិនទាន់បានដាំឈើផ្លែអ្វី ។ លោកអាចយកខ្នុរទៅដាំជុំវិញក៏បានដោយប្រើវិធីដាំបែបឆ្លាស់ធ្មេញត្រី ចន្លោះពីដើមមួយទៅដើមមួយប្រមាណ 7 x 8 ម៉ែត្រ និងត្រូវដាំប៉ុន្មានដើមត្រូវពិចារណាខ្លួនឯង ។ ទោះបីលើភ្លឺស្រះត្រី ឬស្រះទឹក បើលោកដាំខ្នុរខ្លះរមែងបានចំណូលល្អជាងទុកចោលទំនេរ ។ ហើយការដាំខ្នុរនៅលើភ្លឺស្រះទឹក ឬស្រះត្រីនៅប្រកាន់បានថាជាឈើផ្លែដែលសមស្របយ៉ាងខ្លាំងទាំងនេះ ដោយខ្នុរយើងមិនបាច់ត្រូវប្រើជាតិគីមីច្រើនរមែងមិនប៉ះពាល់ ឬផ្តល់ ផលអាក្រក់ដល់ប្រភពទឹក និងត្រីឬសត្វចិញ្ចឹមនៅក្នុងស្រះ តែបើយើងដាំឈើផ្លែដែលមានសត្រូវរុកគួនបំផ្លាញបានងាយ យើងក៏ត្រូវប្រើជាតិគីមីច្រើនតាមនោះដែរ ។ ពិតណាស់ថាជាតិគីមីដែលលោកបាញ់ ឬស្រោចគល់ឈើលើភ្លឺនោះរមែងធ្លាក់ចុះទៅក្នុងទឹក ឬស្រះត្រីបង្ករអោយកើតអន្តរាយដល់សត្វទឹកបានងាយតែខ្នុរយើងស្ទើរពុំប្រើជាតិគីមីសោះក៏ថាបាន ។

## 2. ដាំឆ្លោះ ឬដាំបន្ថែម

ករណីដែលលោកឃើញថាឈើហូបផ្លែ ។ ដែលដាំមុននោះនៅអោយផលល្អ ហើយពុំមានការចាំបាច់នោះមិនត្រូវទៅរំលាយចោលអ្វីទាំងអស់លោកអាចយកដើមខ្នុរ ទៅដាំឆ្លោះក៏បាន ឬដើមឈើផ្លែមុនចាស់ទ្រុឌទ្រោម ឬងាប់ទៅទើបនាំខ្នុរយកទៅដាំជំនួសក៏បាន ។


ដីស្រទាប់លើ
ដីស្រទាប់ក្រោម
រណ្ដៅ
100សម.
100 សម.
ដីរំលោះ
បាតរណ្ដៅ


ពូនដីអោយខ្ពស់ជាងដី
ជុំវិញ 20-30 សម.
① នៅបាតរណ្ដៅដាក់ចំបើង
កំរាស់ 25 សម.
② ដាក់លាមកសត្វ
លាយដីស្រទាប់
លើ 10 សម.
③ ដាក់ចំបើង
កំរាស់ 25 សម.
④ ដាក់លាមកសត្វ
លាយដីស្រទាប់
លើកំរាស់ 10 សម.
រណ្ដៅ

ករណីដែលលោកត្រូវការប្តូរចំការថ្មីពីដើមឈើផ្លែ ឬរុក្ខជាតិផ្សេងៗ តែក្រោយមកបានពិចារណា ហើយថាខ្នុរគួរដាំទើបគឺគឺដាំខ្នុរក្នុងកន្លែងនោះជំនួសឈើផ្លែមុនឬរុក្ខជាតិមុន ។ តែការដាំខ្នុរយើងត្រូវប្រើពេលយ៉ាងតិច 3-5 ឆ្នាំ ទំរាំនិងបានផលលោកក៏មិនត្រូវការកាត់ រំលំរុក្ខជាតិមុនចេញភ្លាម ហើយត្រូវទុកដើមឈើផ្លែមុននៅសិនទំរាំខ្នុរធំឡើង (អាយុ 2-3 ឆ្នាំ) រួចហើយបន្តាក់កាត់រំលំឈើផ្លែមុនចេញម្តងមួយដើមៗ ឬពីរដើមដែលឃើញថាទ្រង់ទ្រាយដើមដុះជិតនិងដើមខ្នុរច្រើនពេក របៀបយ៉ាងនេះលោកគង់ប្រមូលផលឈើផ្លែមុនបានទំរាំខ្នុរផ្តល់ផ្លែបានគ្រប់ដើម ហើយចាំកាត់រំលំឈើមុនទៅ ឬបើហេតុការខាងទីផ្សារផ្លាស់ប្តូរទៅនៅក្នុងផ្លូវដែលល្អរបស់ឈើផ្លែដែលមាននៅមុន លោកអាចប្តូរចិត្តជ្រើសរើសយកឈើផ្លែមុនទុកតទៅជ្រើសកាត់ដើមខ្នុរចោលក៏មិនខូចចិត្តដោយប្រការណាមួយឡើយ ។

ការដាំឈើផ្លែដើមធំដូចជាដើមខ្នុរ យើងគង់មានផ្ទៃដីដែលមានទំនាប រវាងដើមដែលអាចដាក់ផែនការដាំរុក្ខជាតិតបស្មងអ្វីបានទៀតច្រើនយ៉ាង ។ ដូច្នោះចន្លោះការដាំទើបត្រូវដាក់ផែនការទុកមុន គឺយកចន្លោះដែលអាចឆ្ងាយៗល្អ អាចចន្លោះ 8 x 10 ម៉ែត្រ ឬ 10 x 10 ម៉ែត្រ ឬ 10 x 12 ម៉ែត្រ ក៏បាន អ្នកចំការទូទៅក្នុងជនបទប្រកាន់ដើមឈើ " គួបគួរនុង " ការដាំរុក្ខជាតិស្មងក្នុងផ្ទៃដីតែមួយដើម្បីបន្ថែមចំណូលកុំជ្រើសរើសដាំតែឈើដើមតែម្យ៉ាងគត់ ហើយក៏កុំដាំរុក្ខជាតិស្មងតែម្យ៉ាងដោយមិនមានដើមឈើ ព្រោះការចំណាយលើចំការនិងសមាជិកក្នុងចំការនោះមាននៅរាល់ថ្ងៃ ទើបត្រូវចាត់ចែងបែងដាក់ផែនការណ៍ដាំរុក្ខជាតិមានចំណូលជាគោល និងចំណូលបន្ថែមគួបគ្នាទៅ ។ បើពុំដូច្នោះទេចំណូលរបស់ចំការនិងខ្វះខាតទៅដល់កម្មករមិនអាចពង្រីកបានរហូតមួយឆ្នាំ ។

បើដើមខ្នុរក្នុងចំការមាន 10 ដើម ចំណូលមធ្យមក្នុងមួយដើម 800 បាត ។ បើយើងបានចំណូលបន្ថែមមធ្យមក្នុងមួយឆ្នាំ 8,000 បាត ដែលជាចំណូលដែលច្រើនជាងធ្វើស្រែពីររ៉ៃ ហើយឲ្យជាងដាំដំឡូងបីច្រើនរ៉ៃតែម្តង ទាំងនេះគ្រាន់ជាឧទាហរណ៍ស្បើរៀលោកបានពិចារណាការពចំណូលបន្ថែមចំណូល ។ បើពុកម៉ែបងប្អូនកសិករនៅជនបទគិតហើយធ្វើបានដូចនេះអាជីពកសិករគួរធ្វើទៅទៀតបានមិនក្រទេ ។

3. ការដាំខ្នុរប្តូរកដី

កាលណាលោកបានពិចារណា ហើយឃើញថាគួរធ្វើការដាំខ្នុរក្នុងផ្ទៃធំពាំងពីមួយហ៊ិកតាឡើងទៅ (អាចគង់នៅជាំរុក្ខជាតិស្ទួងផ្លាស់ផង) ក៏ត្រូវដាក់ផែនការណ៍ដាំអោយបានច្បាស់លាស់បន្តិច ។

លោកបានដាំដើមតចុះក្នុងកន្លែងដាំតែម្តងតាមចន្លោះដែលត្រូវការ (ចន្លោះ 8x8 ឬ 8x10 ឬ 10x12 ម៉ែត្រ) លុះដើមអាយុបានមួយឆ្នាំទៅពីរឆ្នាំទើបធ្វើការភ្ជាប់ភ្នែក ឬប្តូរត្រួយជាខ្នុរពូជល្អដែលត្រូវការតទៅ ។

ឬដាំពីមែកភ្ជាប់ ឬមែកពូជដែលបានត្រៀមទុកមុន ហើយការដាំរបៀបនេះត្រូវមានការត្រៀមមែកពូជទុកអោយព្រមគ្នា ។

ការចិញ្ចឹមពូជល្អអាចចិញ្ចឹមក្នុងថង់ ឬប្រើខេងតូចៗដាក់ដីនិងកំទេចកំទី (ដីផ្ទាប់ ដីក្រោល) យ៉ាងគ្រប់គ្រាន់ទំរាំដើមពូជខ្នុរដុះលូតលាស់រឹងមាំល្អល្មម ។ ដើមមិនគួរខ្ពស់ជាងមួយម៉ែត្រដោយមើលខ្នាតរបស់ថង់ ឬកន្ទោង ឬខេង ដែលប្រើផ្សាំអោយសមល្មមនិងការលូតលាស់របស់ដើម (បន្ទាប់ពីការផ្សាំក្នុងខេង ឬថង់ឬកន្ទោងមួយឆ្នាំកន្លះ) ការយកទៅដាំនឹងពុំលំបាកពេកទេ ។

ការចិញ្ចឹមមែកពូជបានល្អ គឺយើងគ្រប់គ្រងថែរក្សាយកចិត្តទុកដាក់យ៉ាងសព្វគ្រប់ ។ មុនដាំនៅកន្លែងធំយើងអាចថែរក្សាបានងាយ ហើយចុះកម្លាំងការងារតិចប្រើផ្ទៃដីតូចពេលយើងដាំ យើងត្រូវចែកមែកពូជទាំងនោះអោយឃ្លាតគ្នា ហើយទុកអោយត្រង់មានពន្លឺថ្ងៃបន្ថែមឡើងរហូតដល់ពូជខ្នុរនោះស៊ាំនិងពន្លឺថ្ងៃយ៉ាងល្អ កំឡុងពេលដែលសមស្របចំពោះពេលដាំខ្នុរក្នុងកន្លែងធំនោះប្រមាណដើមខែរដូវភ្លៀងដោយការត្រៀមរណ្តៅដាំអោយព្រមពាំងពីចុងរដូវប្រាំង គឺអាចនៅខែកុម្ភះ ឬមិនា កន្លែងខ្លះអាចមុនរដូវភ្លៀងបន្តិច ។ មុននាំមែកពូជទៅដាំមួយខែ គួរដាក់ជីដែលមានតួលេខក្រោយខ្ពស់លាយទឹកបាញ់មួយសប្តាហ៍ម្តងដូចជា 12-22-32 ។ ជីនេះនិងធ្វើអោយដើមខ្នុរប្រឹងឡើង ហើយគ្រប់គ្រងមិនអោយលាស់ស្លឹកខ្ចីមុនប្រយោជន៍អោយធន់ដល់ការនាំយកទៅដាំប៉ះពាល់ដោយខ្យល់ផាត់ ឬថ្ងៃច្រើនឡើង ។ ចំពោះរដូវដាំដែលសមស្របបំផុត

គឺតាំងពីដើមរដូវភ្លៀង យើងមិនត្រូវការស្រោចទឹក គឺភ្លៀងធ្លាក់អោយជាប្រចាំ បើបានការចាំបាច់ត្រូវស្រោចទឹកក៏ស្រោចមិនញាប់ពេក ព្រោះភ្លៀងធ្លាក់ជួយ ។ ក្នុងការដាំយើងនៅមិនទាន់ដាក់ជីគីមីទេ តែដីដាំក្នុងរណ្តៅដែលត្រៀមមកល្អហើយនោះត្រូវបានដីផ្សំជីព្រោះក្រៅបាតរណ្តៅខ្លះនិងជួយបង្កើការលាស់ស្លឹកថ្មីបានល្អ ។

ខ្ទឹមមិនចូលចិត្តទឹកត្រាំឫសទេមាការលំបាកពេលទឹកលិចឫស ពេលណាឫសត្រាំទឹកហួសពី 2 - 3 ថ្ងៃ នឹងអាក់ការលូតលាស់ភ្លាម ស្លឹកចាប់ពណ៌លឿងឃើញច្បាស់ ។ ទឹកលិចឫសហួសពី 4 ថ្ងៃ ដើមខ្ទឹមនោះអាចងាប់បាន (ចំពោះដើមដែលដាំពីការភ្ជាប់មែក) ។

នេះជាលក្ខណៈសំរាប់អ្នកគិតដាំខ្ទឹមគ្រប់ទីកន្លែង ។ កែប្រែដីអោយធូរ និងមានជីវជាតិទឹកចេញចូលល្អ ។ ក្នុងទីទំនាបត្រូវលើកអោយខ្ពស់ព្រោះជាថា កាលណាបានភ្លៀងធ្លាក់ខ្លាំងគឺរលួយឫសទីទំនាបដីចំការភាគច្រើនស្អិត ទឹកចេញចូលមិនបានល្អត្រូវកែប្រែដីអោយធូរមុនដាំ ។ ទីខ្ពស់ដីអាចលាយខ្សាច់ច្រើនត្រូវកែប្រែឆ្អែប្រឌិតដោយវត្ថុធម្មជាតិជីពួកជីផ្ទាប់ជីគ្រោល ។

ការដាំខ្ទឹមក្នុងកន្លែងទូទៅបើជាកន្លែងដែលធ្លាប់ដាំរុក្ខជាតិផ្សេងៗ ហើយមិនចាំបាច់ត្រៀមដីច្រើនពេកទេ ព្រោះស្អាតបាតហើយគ្រាន់តែកែប្រែមុខដីដោយការភ្ជួររាស់ដាក់ជីព្រោះពោត ឬជីផ្ទាប់ចំការដែលព្រៃដុះថ្មីត្រូវចាំងអោយស្អាតមិនអោយមានឈើផ្សេងៗលាយឡំ ត្រូវភ្ជួររាស់ពីរដងគឺគ្រប់គ្រាន់ហើយ ។ កន្លែងដូចពោលនេះច្រើនជាដីកំណែង ហើយមានវត្ថុធម្មជាតិច្រើន ។ តែទោះជាយ៉ាងណាក៏ដោយបើឃើញថាដីខ្សាច់ខ្លាំង ឬមិនសូវមានវត្ថុធម្មជាតិគួររកមកដាក់បន្ថែមអោយផង មិនថាជាពពួកកាក សំណល់សត្វឆ្អឹងម៉ដ្ឋ កំទេចស្លឹកឈើ ស្មៅដែលពុក កាកសំណល់សំបកសំណែកដី ។ល។ ដែលអាចរកបានយ៉ាងងាយក្នុងភូមិស្រុក ឬ និងកែប្រែជីដោយការដាំរុក្ខជាតិត្រកូលសណ្តែក ហើយធ្វើការភ្ជួរលប់ដីស្រស់អោយពុកនៅក្នុងដីក៏បាន ។ របស់ផ្សេងៗទាំងនេះនិងជួយអោយដីក្លាយជាដីកំណែងអោយការចេញចូលទឹកនិងអាកាសធាតុក្នុងដីល្អ ដីជាប់ទឹកល្អតែមិនត្រូវជោគជាំឡើយ ។

ដាំខ្នុរក្នុងទីទំនាបទឹកលិចដល់ ត្រូវដាំលើរងដូចគ្នានិងរងបន្លែ ដើម្បីមិនអោយទឹកលិចដល់គល់ រងចំការ និងងាយស្រួលក្នុងការបញ្ចេញ បញ្ចូលទឹក ខ្នាតរបស់រងគួរទទឹងយ៉ាងតិច 6 ម៉ែត្រ ប្រឡាយទឹកទទឹង 1.50 ម៉ែត្រ បណ្តោយរងស្រេចតែផ្ទៃដីខ្នងរងរឹតតែខ្ពស់រឹតតែល្អ ខ្នុរនិងបានដុះលូតលាស់យ៉ាងពេញទី កាលណាជីករងស្រេចហើយក៏កែប្រែដីដោយការជីកដីហាលដាក់ជីក្រោលចាស់ៗជីផ្ទាប់ ដើម្បីអោយដីធូរក្នុងពេលដែលឃើញថាដីស្អិតខ្លាំងគួរដាំរបស់ផ្សេងៗ ឬ ដាំបន្លែសិន 2 - 3 ឆ្នាំមុនធ្វើអោយដីធូរល្អឡើងទើបចាំដាំដើមខ្នុរជាក្រោយ ។

ចន្លោះនៃការដាំ

ការដាំខ្នុរបែបលើករង និងការដាំក្នុងទីខ្ពស់គួរដាំជាជួរដើម្បីងាយស្រួលក្នុងការថែរក្សារ និងធ្វើកិច្ចការចំការផ្សេងៗចន្លោះចម្ងាយរបស់ដើម ឬរណ្តៅ 8 x 8 ឬ 10 x 10 ម៉ែត្រ ជាចន្លោះដែលសមស្របសំរាប់ការដាំបែបរងចន្លោះរវាងដើមអាចញឹកជាង នេះក៏បាន សំរាប់ទីខ្ពស់គួរមានចន្លោះ 10 x 10 ម៉ែត្រ ។

រយះដាំប្រើចន្លោះ 8 x 8 ម៉ែត្រ មួយរ៉ៃដាំបាន 25 ដើមតែបើត្រូវការដាំមួយរ៉ៃអោយបាន 30 ដើមអាចប្រើចន្លោះដាំ 8 x 8 ម៉ែត្រក្នុងមួយជួរ ឆ្លាស់ដោយចន្លោះដាំ 5 x 5 ម៉ែត្រទៀតពីរជួរ ហើយរំលងរយះដើមជួរទៅទៀត 15 ម៉ែត្រ ទើបដាំជួរទីបួន ជាចន្លោះ 8x8 ម៉ែត្រឆ្លាស់គ្នាទៅ ដូចនេះក៏បានមួយរ៉ៃ 30 ដើម (ដោយដាំបែបឆ្លាស់ធ្មេញត្រី) ។

រណ្តៅដាំគួរជីកអោយមានខ្នាតទទឹង បណ្តោយ ជំរៅប្រមាណ 50-100 សង្ទីម៉ែត្រ ទាំងស្រេចទៅលើសភាពល្អឬអាក្រក់របស់ដី ។ បើដីធូរហើយមានវត្ថុធម្មជាតិច្រើនជីករណ្តៅខ្នាត 50 សង្ទីម៉ែត្រក៏បាន ចំការដែលដីមិនសូវល្អការជីករណ្តៅមានខ្នាតទូលាយ ដើម្បីកែប្រែដីក្នុងរណ្តៅដាំអោយល្អ ដីដែលជីកឡើងមកពីរណ្តៅគួរចែកជាពីរផ្នែក គឺដីជាន់លើមួយផ្នែក និងដីជាន់ក្រោមមួយផ្នែកទៀត ហាលដីដែលជីកឡើងមក 15-20 ថ្ងៃទើបផ្សំដីក្នុងផ្នែកជាមួយជីគ្រោល ឬជីផ្ទាប់និងជីហ្វូសហ្វាត ប្រមាណ 1-2 កំប៉ុងល្មមធូរល្អលុបផ្នែកដីជាន់លើចុះទៅមុនលុបដី

ដាន់ក្រោមចុះទៅ ក្រោយនិងសង្កេតឃើញថាដីដែលលុបចុះទៅខ្ពស់ហួសមាត់រណ្តៅឡើងមក ទុកចោលអោយដីស្រុតចុះជាមុនសិនទើបដាក់ដាំ ។

ដាំក្នុងរដូវភ្លៀង ការដាំខ្នុរត្រូវអនុវត្តន៍ដោយការប្រុងប្រយ័ត្នកុំអោយឫសដាច់ច្រើនដើមនិងស្ទះការលូតលាស់ ដើមខ្នុរដែលដាំទុកក្នុងថង់យូរដីនិងចាប់គ្នារឹង ហើយឫសនិងរុំគ្នាច្រើនពេលដែលដាំត្រូវយកចេញពីថង់ប្លាស្ទិក ឬកន្ទោង ហើយត្រូវដីច្របាច់ដីបាតថង់អោយបែកចេញពីគ្នាបន្តិចបន្តួចអោយឫសដែលចាក់ទៅអាចលាចេញខ្លះ ដើម្បីធ្វើអោយការលូតលាស់បានលឿន ។

ការដាំដោយមែកភ្ជាប់ត្រូវដាំក្នុងលំដាប់ដីក្នុងថង់មុន ឬខ្ពស់ជាងដើមបន្តិចបន្តួច តែកុំអោយជិតកន្លែងតដើម្បីមើលឃើញថាមែកដែលបែកចេញមកនោះជាមែកដើមត ឬមែកពូជបើបែកចេញមកពីដើមតត្រូវក្តិចចោល ។

កាលណាដាំរួចហើយ រកឈើមកដោតជាបង្គោលចងការពារខ្យល់យោក រួចស្រោចទឹកភ្លាមអោយជោគ ហើយរកធាងដូងមកជួយបាំងថ្ងៃខ្លះក្នុងពេលដំបូងរិតតែល្អ ព្រោះបើថ្ងៃខ្លាំងក្នុងពេលដំបូងដើមពូជអាចស្រពោនអាក់ការលូតលាស់ ក្រោយពីនោះបើភ្លៀងមិនធ្លាក់ ចាំថែរក្សាស្រោចទឹកជានិច្ច ការប្រើចំបើងឬស្មៅគ្របដីគល់ដើម ដើម្បីជួយថែរក្សាសំណើមក្នុងដីបរិវេណគល់អោយបានល្អតែបើភ្លៀងជោកជាំត្រូវយកចំបើងចេញ និងជួយកុំអោយគល់សើមខ្លាំងពេក ។

# 7. ការកាត់តែងមែក

ខ្នុរជាឈើហូបផ្លែរស់នៅប្រទេសដែលមានអាកាសធាតុក្តៅ មិនជំរុះស្លឹក រាងដើមធំ ចេញផ្កាចេញផ្លែតាមបរិវេណគល់ ឬមែកធំៗ ។ ដោយធម្មជាតិដើមខ្នុរជាដើមឈើដែលមានរាងដើមធំល្មម ឱកាសដែលពន្លឺថ្ងៃចាំងដល់គល់ពុំបានល្អ បើគ្មានការកាត់តែងមែកនិងពេលភ្ញែកផ្កាចំរាញ់អាហារមានតិចផលនៃការកាន់ផ្កា កាន់ផ្លែតិចតាមនោះដែរ ។ ផ្សិនិងខ្នុរជុះភ្ញែកផ្កាត្រង់ចំណែកគល់ បើដើមណែនក្រាស់ពេកពន្លឺថ្ងៃចាំងចូលមិនដល់ជាឱកាសដែលជំងឺផ្សិតចូលទៅបំផ្លាញផ្កានិងផ្លែអោយខូចខាតបានងាយ ។

លក្ខណៈទ្រង់ទ្រាយដើមខ្នុរពូជខ្លះ

ពូជ ហ្វាថាឡុម ត្ូវដើមខ្ពស់ធំលក្ខណៈបែកមែកខ្នែងធំ ទូទៅមុំនិងដើមមិនធំឬមិនតូច មែកវែងបន្តិចរៀងគ្នាមិនសូវមានរបៀបទ្រង់ទ្រាយទេដើមស្រឡះ ។

ពូជចំប៉ាក្រប តូដើមធំខ្ពស់មធ្យម ទាបជាងពូជហ្វាថាឡុម មានលក្ខណៈការបែកមែកខ្នែងធំទូទៅមានបង្គាបធំល្មមមែកវែងមធ្យម មានកល្អណៈរៀងល្អ មែកមិនសូវមានរបៀបទ្រង់ទ្រាយដើមច្រើនណែនក្រាស់ផង ។

ពូជថងស៊ុតថៃ តូដើមធំស្រដៀង ហ្វាថាឡុមលក្ខណៈការបែកមែកខ្នែងធំៗ ទូទៅស្រដៀងហ្វាថាឡុមទ្រង់ទ្រាយដើមក្រាស់ពេក ។

ពូជអ៊ីថវ តូដើមខ្ពស់មានលក្ខណៈការបែកមែកខ្នែងធំ បង្គាបធំការចាត់រៀងមែកមានរបៀបមែកវែងទ្រង់ទ្រាយដើមណែនក្រាស់ប្រហាក់ប្រហែលហ្វាថាឡុម ។

ពូជដែងរស្មីគួដើមខ្ពស់លក្ខណៈការចាត់រៀងមែកមានរបៀបតិចតួច ទ្រង់ទ្រាយដើមណែនបន្តិច ពូជតាបួយ លក្ខណៈដើមទ្រង់ទ្រាយដើម និងការបែកមែកស្រដៀងទៅនិងហ្វាថាឡុម ។

## វិធីការកាត់តែងមែកខ្នុរ

1. ក្នុងឆ្នាំដំបូងត្រូវកាត់ចុងកណ្តាល (ក្តិចត្រួយ) ដើម្បីអោយមែកបែកខ្នែងខាង ហើយជ្រើសរើសមែកខ្នែងដូចពោលទុកប្រមាណ 3-4 មែកដោយជ្រើសរើសមែកដែលល្អ បង្គាប ទូលាយក្នុងកំឡុងឆ្នាំដំបូងកុំអោយពន្លកដើមតដុះប្រណាំងនិងត្រួយពូជល្អ ។ បើបែកចេញមកត្រូវក្តិច ចោលភ្លាមបរិវេណគល់ពីលំដាប់ដីឡើងទៅ 35 សង្ទីម៉ែត្រ មិនត្រូវទុកមែកទេ ករណីមែកពូជមានខ្នែងសមស្រប ហើយជ្រើសរើសមែកនោះទុកដោយមិនត្រូវកាត់ត្រួយកណ្តាលចេញឡើយ ។

2. ក្នុងឆ្នាំទី 2-3 ទុកអោយមែកខ្នែងដែលជ្រើសរើសទុកដុះដល់ផុត តែបើមានមែកខ្នែងតូចបែកពីមែកខ្នែងធំណែនក្រាស់ពេក ត្រូវកាត់មែកខ្នែងតូចចេញខ្លះ គឺត្រូវកាត់មែកតូចដែលមានបង្គាបតូចមែកតូចដែលដុះចេញត្រួតគ្នា (កាត់មែកក្រោមចេញ) ឬមែកដែលដុះក្នុងដែលច្រើនធ្វើការកាត់តែងមែកពួកនេះចេញមុនដាក់ជីលើកទីពីរ ។

3. កាត់តែងមែកដែលមានជំងឺ រហែក បាក់ ងាប់ មែករំពង់ នៅពេលក្រោយប្រមូលផលហើយ ។ បើបានអនុវត្តនិការកាត់តែងមកតាំងពីឆ្នាំដំបូង១ក្នុងឆ្នាំត១ទៅ និងធ្វើការកាត់តែងមែកត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ។

4. បើទ្រង់ទ្រាយដើមណែនពេក ពន្លឺថ្ងៃចាំងចូលមិនគ្រប់គ្រាន់ត្រូវកាត់តែងមែកខ្នែងតូច១ដែលដុះជិតគ្នាច្រើនពេកទៀត ការពិចារណាថាការកាត់តែងមែកដើម្បីអោយមានពន្លឺថ្ងៃចាំងច្រើនតិច ហើយសព្វដើមឬមិនសព្វនិងគ្រប់គ្រាន់ក្នុងការការកាត់តែងមែកបុណ្ណាដោយពិចារណា ក្រោយពីការកាត់តែងរួចហើយសម្លឹងកាត់ទ្រង់ទ្រាយដើម អោយបានប្រមាណ

25-30% នៃបរិមាណទ្រង់ទ្រាយដើមទាំងអស់  ពេលធ្វើការកាត់តែងមែកក៏ត្រូវខំសង្កេតមើលផង្គូវបោះដើមផងរួចរកវិធីកំចាត់ទៅព្រមគ្នាតែម្តង ។



# ៨. ខ្នុរចូលចិត្តទឹក តែមិនធន់និងទឹកដក់ជាំឫស

វត្ថុមានជីវិតទាំងរុក្ខជាតិ និងសត្វអត់ទឹកមិនបានជាដាច់ខាត ។ ខ្នុរក៏ដូចគ្នាដែរ ទោះជាខ្នុរមិនចូលចិត្តទឹកដក់នៅឫស តែខ្នុរលូតលាស់បានក៏ដោយសារទឹកជាវត្ថុសំខាន់ ។ ដើមឈើដែលយើងឃើញថាធន់និងការរាំងស្ងួតគឺដើមស្ដៅ ដើមស្ដៅធន់និងភាពរាំងស្ងួតណាស់ រដូវក្ដៅខ្លាំងពេលផ្សេងៗច្រើនប្ដូរពណ៌ ឬជ្រុះស្លឹកតែដើមស្ដៅនៅតែខៀវស្រងាត់ ។

ដើមផ្លែដែលធន់និងរដូវប្រាំងល្អគឺអំពិល ។ ចំណែកខ្នុរគឺធន់និងរដូវប្រាំងបានតែពុំសូវល្អទៀតហើយទប់ទល់និងស្ងួតយមិនបាន ទោះជាយ៉ាងណាក៏ដោយ បើទុកអោយស្ងួតហួសពេកអាចផលប៉ះពាល់ដល់ការចេញផ្កាបានមកពីឫសខ្នុរច្រើនរកស៊ីនៅក្នុងដីជាប់រាក់ជាង ស្វាយនោះឯងខណៈជាឫសឬឫសខ្នុរអាចបែកជាឫសជញ្ជាំរកសំណើមនិងការពារគេរពីរលើពាសល្អ ដូច្នេះខ្នុរនិងលូតលាស់បានល្អពេលចូលរដូវភ្លៀង ហើយអាក់ការលូតលាស់ពេលរដូវប្រាំង ស្លឹកខ្លះលឿង ខ្លះជ្រុះតែមិនដល់ងាប់ទេ ។

រដូវប្រាំងត្រូវប្រើចំបើង ឬស្មៅគ្របគល់ដើម្បីកុំអោយសំណើមបាត់បង់លឿនពេក ស្រោចទឹកហើយយកវត្ថុទាំងនោះគ្រប អាចត្រូវស្រោចទឹករាល់ៗ 5-7 ថ្ងៃម្ដង តែបើមិនគ្របគល់អាចស្រោចទឹករៀងរាល់ថ្ងៃ ។

ខ្នុរដាំថ្មីបើភ្លៀងមិនធ្លាក់ត្រូវសង្កេតមើលដីថា តើដីស្ងួតឬរាត់ បើដីនោះស្ងួតត្រូវស្រោចទឹកអោយពីរថ្ងៃម្ដង ឬបីបួនថ្ងៃម្ដងក៏បាន ដោយស្រោចអោយដីសើមគ្រប់គ្រាន់ទោះបីខ្នុរមិនចូលចិត្តទឹកដក់ក៏ដោយ តែបើទុកអោយដីស្ងួតខ្វះទឹកក៏មិនបានដូចគ្នា ខ្នុរលូតលាស់ល្អកាលណាបានទទួលពន្លឺថ្ងៃខ្លាំងនិងមានសំណើមខ្ពស់ (កុំអោយទឹកដក់ឫស) ។

ខ្នុរចេញផ្កាពីរដងគឺពេលដំបូងប្រមាណចុងខែឧសភា ឬ ខែ មិថុនា និងលើកទីពីរចេញតាំងពីខែកញ្ញាចុងខែវិច្ឆិកា ។

ខ្នុរដែលចេញ ផ្កាលើកដំបូងប្រមាណនៅចុងខែ ឧសភា ហើយច្រើនប្រទះនឹងការខ្វះខាតទឹកក្នុងកំឡុងខែកក្កដា ដែលជាពេលដែលភ្លៀងរាក់ខានមួយរយៈតូច ។ កំឡុងពេលដូចពោលនេះខ្នុរនៅជាផ្លែខ្ចី បើខ្វះទឹកក្នុងពេលនោះផ្លែខ្នុរនឹងលូតលាស់មិនបានល្អ នរណាផ្តល់ទឹកអោយពេលនេះជាការល្អ ។ អាចជាក់អោយផ្លែលូតលាស់និងពង្រីកខ្លួនលឿន ។ ផ្លែខ្នុរដែលខ្វះទឹក សាច់ក្លែបស្តើង ផ្លែតូចមិនរីកធំ ។

ខ្នុរដែលចេញផ្កាលើកទីពីរកំឡុងខែកញ្ញា ។ ដើមខែវិច្ឆិកាជាកំឡុងការលូតពកាត់របស់ផ្លែខ្ចី ពេលចូលរដូវរងារដល់រដូវប្រាំងក៏ជាពេលដែលខ្វះទឹក ភ្លៀងទៀតដូចគ្នា ខ្នុរលើកទីពីរនេះនិងទុំម្តងនៅខែមេសាដើមខែមិថុនា កំឡុងផ្លែខ្ចីខ្វះទឹករមែងផ្តល់ផលអោយមិនបានដូចគ្នា បើយើងឃើញថារហូតកំឡុងពេលលូតលាស់របស់ផ្លែខ្ចី ផ្លែឈើចាស់ និងចំពោះឈើផ្លែគ្រប់ប្រភេទដូចគ្នាទាំងអស់គឺត្រូវការទឹកច្រើន ។

ទោះបីខ្នុរជាឈើផ្លែដែលធន់និងការរាំងស្ងួតបានល្អសមគួរ តែបើខ្វះទឹកនៅពេលខ្ចី ហើយផលិតផលរមែងមិនបានល្អ ខ្នុរនៅពេលពុំទាន់ចាស់បន្លាស្រួចនៅជិតគ្នា តែដល់ពេលចាស់បន្លានោះនិងឃ្លាតពីគ្នាហើយពេលបន្លាចាប់រីកចេញអោយបញ្ឈប់ការអោយទឹកភ្លាម (ប្រមាណ 20-30 ថ្ងៃមុនប្រមូលផល) ដើម្បីបន្ថយបរិមាណទឹក ឯសាច់ក្លែបមានភាពផ្អែមចាប់បន្ថែមឡើងសាច់មិនជោរទឹកពេក ។

តាំងពីផ្កាខ្នុរចាប់ផ្តើមផ្សំភេទ រហូតដល់ប្រមូលផលបានប្រើវេលាប្រមាណ 8 ខែពេញ បើពន្យាអោយអាយុផ្លែទៅដល់ 9 ខែ ត្រូវស្រោចទឹកបន្តដើម្បីពន្យាពេលទុំ ។

ខ្នុរដែលនិងពន្យាពេលទុំបានគឺខ្នុរចេញផ្កាលើកទីមួយផ្តល់ផលប្រមាណខែមករា ដែលធម្មតាខ្នុរនៅទីផ្សារចង់អស់មានលក់ ហើយយើងមិនចាំបាច់ចាំពន្យាពេលទុំរបស់ផ្លែ តែយ៉ាងណាបើខ្នុរលើកទីពីរដែលដើមខ្លះអោយចេញផ្កាខ្លះៗ នៅខែវិច្ឆកាដល់ខែតុលា ដែលផ្លែនិងចាស់ម្តយៗនៅខែឧសភាដល់ខែមិថុនា ជាពេលដែលភ្លៀងចាប់ផ្តើមធ្លាក់ បើប្រមូលផលពេលនោះគុណភាព

ក្លែបនិងភាពផ្អែមនិងថយចុះ ព្រោះបានទទួលទឹកច្រើន ។ ខ្នុរពេលនោះរហូតរដូវក្តៅត្រូវអោយទឹកតទៅយ៉ាងគ្រប់គ្រាន់ ដើម្បីពន្យាពេលទុំដល់រដូវភ្លៀងផ្គរក (កក្កដា) ភាពផ្អែមនិងបន្ថែមឡើងព្រោះបើទុកអោយចាស់ តាមធម្មជាតិវានិងអាចទុំនៅពេលចាប់ភ្លៀងដំបូងល្មមដែលភាពផ្អែមនិងថយចុះ (ចុងខែឧសភា ខែមិថុនា) តែបើផ្តល់ទឹកតទៅនិងពន្យា ពេលទុំបានទៀត (15-30 ថ្ងៃ) ។

រយះពេលចេញផ្ការបស់ខ្នុរនោះមិនព្រមគ្នា ដោយហេតុនេះរដូវកាលរបស់ខ្នុរទើបវែងដល់ 6 ខែក្នុងឆ្នាំមួយៗបើបេះយកខ្នុរលើកណាទុក ត្រូវធ្វើអោយតាមដំណាក់ការដូចរៀបរាប់ ដើម្បីជៀសវាងបញ្ហាខ្នុរសំបូរច្រើននៅតាមទីផ្សារ ក្នុងរដូវកាលធម្មតានិងជៀសវាងបញ្ហាការប្រមូលផលក្នុងកំឡុងខែភ្លៀង ដែលភាពផ្អែមនិងថយចុះ លុះដល់ខ្នុរតាំងពីចេញផ្កាផ្សំជាប់ ហើយប្រើពេល 4-7 ខែ (អាស្រ័យលើពូជ) ដល់ប្រមូលផលបាន លោករាប់មើលថាផ្កាឈុតណាទៅចាស់កំឡុងខែណា ។

ការផ្តល់ទឹកដើម្បីចិញ្ចឹមផ្លែខ្ចីលើកដំបូង អាចមានផលប៉ះពាល់ដល់ការជាប់ផ្ការបស់ផ្លែលើកក្រោយៗបានមកពីខ្នុរបណ្តក់ផ្កាការចេញផ្កា ពោលគឺខ្នុរបានទទួលទឹកច្រើន ហើយនិងមានផលធ្វើអោយលាស់ស្លឹកខ្ចី ច្រើននិងធ្វើអោយផ្កាក្នុងឈុតនោះជ្រុះបាន ។ ដើមណេះមែងទម្លាក់ផ្លែ ឬផ្កាចោលសិន ដើម្បីអោយស្លឹកលូតលាស់តទៅ ហើយទម្លាក់ស្លឹកចោលសិន ដើម្បីរក្សាមែកធាងសាខាដើមវាទៅតាមច្បាប់ធម្មជាតិដែលត្រូវលះបង់ ផ្នែកមួយរួមដែលមិនចាំបាច់ចោលសិនអោយសល់តែផ្នែកដែលសំខាន់ទៅតាមលំដាប់ ។

ដូច្នេះការអោយទឹកដើម្បីចិញ្ចឹមផ្លែក្នុងមួយដងៗ ដែលជាប់ផ្លែនោះត្រូវគឺតទុកជានិច្ចថាទឹកជាវត្ថុបង្កំអោយលាស់ស្លឹកខ្ចី ហើយជំនួសអាហារទៅចិញ្ចឹមផ្លែក៏ត្រូវទាញទៅចិញ្ចឹមស្លឹកខ្ចីសិនអាចអោយផ្លែខ្ចី ឬផ្កាឈើក្រោយជ្រុះបាន ។ គួរផ្តល់ទឹកតិច ស្រោចជុំវិញដើមជាយៗ ដើម្បីអោយទឹក ទៅចិញ្ចឹមផ្លែឈុតដំបូងបានខ្លះ តែមិនច្រើនពេកដែលគ្រាន់តែជាស់អោយលាស់ស្លឹកខ្ចីបាន ។

មុនប្រមូលផល 10-15 ថ្ងៃត្រូវឈប់ស្រោចទឹកជាដាច់ខាត ដើម្បីអោយសាច់ផ្លែបានប្រមូលម្សៅនិងទឹកបានច្រើនភាពផ្អែមនិងមានល្អឡើង ។



# 9. ការដាក់ជីលើដំណាំខ្នុរ

សភាពដីល្អមានវត្ថុសរីរាង្គច្រើន ខ្នុរតែងតែលូតលាស់ល្អ ដីធម្មជាតិផ្សេងៗដូចជា ដីក្រោល ជីផ្ទាប់ កំទេចកំទីស្លឹកឈើ ស្មៅស្ងួត ដែលរលួយល្អ ហើយរួមទាំងជីវក្ខជាតិស្រស់ដែលបានមកពីការដាំរុក្ខជាតិគ្រួសារសណ្តែក ហើយភ្ជួររាស់ កប់ សុទ្ធតែជាអាហារសំរាប់ដើមឈើ ថែមទាំងជួយអោយដីធូរទៀតផង ។

ខ្នុរដែលដាំពីមែកតគួរផ្តល់ផលនៅឆ្នាំទី 4 ហើយខ្នុរដែលដាំពីគ្រាប់គួរផ្តល់ផលក្នុងឆ្នាំទី 6 យ៉ាងយឺតបើខ្នុរលូតលាស់ធម្មតាគឺមិនល្អពេក ឬមិនក្រិនពេក ។

ខ្នុរដែលលូតលាស់ដល់ឆ្នាំដែលគួរនិងផ្តល់ផលបាននោះ បើលូតលាស់ស្មោគស្លឹកព្រោះបានទទួលជីនិងទឹកច្រើន ខ្នុរនឹងមិនអាចចេញផ្លែបានក្នុងឆ្នាំនោះទេ មកពីធាតុអាហារត្រូវបញ្ជូនឡើងទៅសាងមែកធំនិងបរិវេណគល់ ។ ដូចនោះមុនដល់ពេលចេញផ្កាត្រូវបន្ថយបរិមាណជីពួកនីត្រូសែនចុះគឺបញ្ឈប់ពួកជីផ្ទាប់ជីក្រោលរយៈពេលប្រហែលពីរខែមុនរដូវចេញផ្កា ព្រមទាំងបន្ថយបរិមាណទឹកផងដើម្បីកុំអោយស្លឹកច្រើនពេក ។

ខ្នុរដែលផ្តល់ផលហើយត្រូវដាក់ជីផ្ទាប់ ជីគ្រោលក្នុងមួយឆ្នាំម្តង គឺក្រោយពីប្រមូលផល ហើយត្រូវយកជីប្រភេទនេះទៅគរទុកជុំវិញគល់ប្រមាណ 4 កណ្តុប មួយកណ្តុបកន្លះបោ៉ត ឬអាស្រ័យទៅលើខ្នាតរបស់ដើម ធំឬតូចប៉ុណ្ណាដាក់ជីច្រើនឬតិចប៉ុណ្ណោះ ហើយឆាយដីជាចង្អូរជុំវិញដើមកាលណាភ្លៀងធ្លាក់ដំបូងមក ជីនិងជ្រាបធ្លាក់ចុះទៅក្នុងចង្អូរនោះ ។

ជីផ្ទាប់ ជីគ្រោល មិនត្រូវដាក់នៅពេលមានភ្លៀងធំ (សីហា-កញ្ញា) ព្រោះជាពេលភ្លៀងធ្លាក់ជោគជាំធ្វើអោយដុះបទឹកច្រើន អាចរលួយឫសបាន ត្រូវដាក់ជីគីមី 15-15-15 ក្នុងកំឡុងដើមខែភ្លៀងធំក្នុងមួយដើម 1-2 គីឡូក្រាម ( អាយុបាន 7 ឆ្នាំឡើងទៅ ) ហើយដាក់ជី 13-13-21 កំឡុងចុងខែភ្លៀងមួយដងទៀតមួយដើម 1 - 2 គីឡូក្រាម ដូចគ្នា ។

យើងល្បងមើលតួនាទីធាតុអាហារខ្លះដែលមានផលដល់ខ្នុរ ៖

## ធាតុនីត្រូសែន

ដោយខ្នុរជាឈើផ្លែដែលមានប្រព័ន្ធ ឫសជញ្ជក់នៅក្នុងលំដាប់រាក់ទើបអាចស្រូបយកធាតុអាហារទៅប្រើបានល្អ តួនាទីរបស់នីត្រូសែននោះបាននិយាយច្រើនដងហើយក្នុងសៀវភៅផ្សេងៗ ដែលយើងធ្លាប់បោះពុម្ពហើយទើបគ្រប់គ្រាន់តែរៀបរាប់ត្រួសៗថា នីត្រូសែនមានការចាំបាច់ដល់ការលូតលាស់ផ្នែកដើមមែកធាងសាខា និងកំឡុងការកាន់ផ្លែគឺតាមគោលការណ៍ដាក់ជីលើផ្លែនោះ បើជាដើមឈើដែលទើបនិងដាំពុំទាន់កាន់ផ្លែ ជីនីត្រូសែនមានតួនាទីខ្ពស់បំផុតគឺ តារាងមាត្រដ្ឋាន តែការប្រើជីនីត្រូសែនក្នុងធាតុទោលមិនត្រូវ ប្រើក្នុងមួយមុខនេះច្រើនពេកទេ ព្រោះធ្វើអោយដើមឈើផ្លែលូតលាស់លឿនពេក មែកនិងស្លឹកខ្ចីលូតលូន់មិនល្អ ហើយជាំស្លឹកបានងាយ ដូច្នោះត្រូវប្រើជីគីមីផ្សំផ្សេងៗដែលមានធាតុនីត្រូសែនខ្ពស់ជាង ឬស្មើគ្នា និងហ្វូសហ្វ័រ ឬ ប៉ូតាស្យូម ដូចជារូបមន្ត 15 -15-15 ឬ 16-16-16 ឬ 20-20-20 ឬ 20-11-11 ឬ12-3-6 ការប្រើជីផ្ទាប់ជីគ្រោល ឬជីអាចមិប្រជៀវទាំងនេះសុទ្ធតែមានធាតុនីត្រូសែនទាំងអស់ ។

បើយើងដាំខ្នុរពីមែកត ឬភ្ជាប់ភ្នែក ឬភ្ជាប់ខាងតាំងពីដាំទៅបានអាយុ 3 ឆ្នាំហើយ ក្នុងឆ្នាំទី 4 ខ្នុរដើមនោះនិងត្រូវផ្តើមចេញផ្កាកាន់ផ្លែ ហើយការប្រើជីនីត្រូសែននៅក្នុងកំឡុងបីឆ្នាំដំបូងតែគំរប់ចូលឆ្នាំទី 4 ត្រូវពិចារណាមើលថាបើ ប្រើជីដែលមានធាតុនីត្រូសែននោះគង់និងធ្វើអោយខ្នុរដើមនោះស្ទោកស្លឹក ត្រូវបន្ថយតួនាទីនីត្រូសែនចុះអោយបានច្រើន បើទុកអោយធាតុនីត្រូសែនបញ្ចេញតួនាទីរបស់វាតទៅ អាចមិនចេញផ្កាកាន់ផ្លែក្នុងឆ្នាំទី 4 ក៏មាន ព្រោះរវល់តែសាងមែកធាង និងស្លឹក ។ ខ្នុរដែលល្អស្លឹកច្រើនពេក និងកាន់ផ្លែយឺតជាងរួមទាំងការផ្តល់ទឹករហូតរមែងគាំទ្រការលូតលាស់ផ្នែកមែកស្លឹក ។

សូម្បីតែនីត្រូសែនមានតួនាទីសំខាន់ក៏ត្រូវចេះ ប្រើវាដែរ ។

## ធាតុហ្វូសហ្វ័រ

ដីនៅក្នុងប្រទេសថៃភាគច្រើនខ្វះធាតុ ហ្វូសហ្វ័រដែលជាប្រយោជន៍ចំពោះដើមរុក្ខជាតិមិនសូវមានដីឯណាដែលមានធាតុហ្វូសហ្វ័រ ។ ដីអាស៊ីដច្រើនក៏រឹតតែខ្វះធាតុហ្វូសហ្វ័រ ដែលរុក្ខជាតិនាំទៅប្រើជាប្រយោជន៍ដូចជា ដីឯវាលទំនាបភាគកណ្ដាលជាង 5 លាន ៨ សែន រ៉ៃ ដែលជាអាស៊ីដខ្លាំង និងដីដែលមានពណ៌ក្រហមខ្លាំងនោះមានធាតុហ្វូសហ្វ័រ ដែលជាប្រយោជន៍ដល់រុក្ខជាតិតិចណាស់ ព្រោះហ្វូសហ្វ័រក្នុងដីដូចពោលនេះមិនអាចបញ្ចេញអោយរុក្ខជាតិនាំទៅប្រើប្រយោជន៍បានឡើយ ។

ធាតុហ្វូសហ្វ័រគាំទ្រអោយស្លឹកធ្វើសំយោគពន្លឺបានល្អឡើង ទើបមានការប្រមូលផ្ដុំអាហារបានល្អមានផលដល់ការជាស់អោយឈើផ្លែ នោះត្រៀម ខ្លួនសំរាប់ការចេញផ្កា បើខ្វះធាតុហ្វូសហ្វ័ររុក្ខជាតិនិងចេញផ្កាយឺតជាងធម្មតា ឬចេញផ្លែមិនបានល្អ ។

ការប្រើជីគ្រប់ទាំងបីធាតុ គឺមានទាំងនីត្រូសែនហ្វូសហ្វ័រ និងប៉ូតាស្យូមក៏និងមានហ្វូសហ្វ័រជានិច្ចដែរ ដូចជា 16-16-16 ឬ 15-15-15 ឬ 20-20-20 ធាតុទាំងបីស្មើគ្នា តែបើធាតុនីត្រូសែនល្មមហើយយើងគួរប្រើជីដែលមានធាតុនីត្រូសែនទាបជាងហ្វូសហ្វ័រ ។

ធាតុនីត្រូសែន និងប៉ូតាស្យូម រុក្ខជាតិនាំទៅប្រើបានច្រើនជាង និងមានការបាត់បង់បានលឿនជាងធាតុហ្វូសហ្វ័រពេលដាក់អោយរុក្ខជាតិ តែហ្វូសហ្វ័រច្រើនត្រូវគ្រាប់ដីពោងទុក ដូច្នោះមានការសេសសល់ក្នុងដីច្រើន ។ ដូចនេះការប្រើជីហ្វូសហ្វ័រខ្ពស់ យើង និងមិនប្រើរាល់ឆ្នាំ តែនិងប្រើរាល់ 2-3 ឆ្នាំ ។ ការប្រើជីហ្វូតស្វាត (អោយធាតុហ្វូសហ្វ័រ) ច្រើនដាក់អោយដើមឈើផ្លែរាល់ៗ 2-3 ឆ្នាំដោយការប្រមូលផ្ដុំនៅក្នុងដីបានច្រើនឆ្នាំជានិច្ច ។ ការដាក់ជីហ្វូសស្វាតរាល់ឆ្នាំមានផលដូចគ្នានិងប្រើហ្វូសស្វាតរាល់ៗ 2-3 ឆ្នាំដូច្នេះការប្រើជីហ្វូសស្វាតរាល់ឆ្នាំជាការចុះសាហ៊ុយ ។

ទោះបីជាយ៉ាងណាក៏ដោយ ជីហ្វូសស្វាតប្រភេទខ្លះដែលមិនមានធាតុផ្សំរបស់កាល់ស្យូម (ថ្ម កំបោរ) កាលណាដាក់ចុះទៅក្នុងប្រភពដីដែលជាអាស៊ីដបានទទួលផលប្រយោជន៍តិចណាស់ ត្រូវកែប្រែសភាពដោយប្រើថ្មកំបោរ ឬកំបោរសដើម្បីបន្ថយសភាពជាអាស៊ីដរបស់ដី តែការប្រើកំបោរសត្រូវប្រើតាមក្រិតក្រំដែលសមរម្យ កុំអោយដីមានជាតិកំបោច្រើនពេកតែធ្វើអោយដីជាបាស់ ។ បើប្រើជីហ្វូសស្វាត ឬអាចម៍ប្រជៀវ ជីហ្វូសស្វាតទាំងនេះជាចំណែកផ្សំរបស់ពួកកាល់ស្យូម ថ្មកំបោរស្រេច ។ ហើយដើម្បីជួយកែប្រែសភាពជាតិអាស៊ីដរបស់ដីផង បើប្រើជីនេះមិនត្រូវប្រើកំបោរសកែជាតិអាស៊ីដទៀតក៏បាន ។ តែគួរប្រើជីថ្មហ្វូសស្វាត ឬអាចម៍ប្រជៀវដាក់អោយដើមឈើល្អជាង ការកែប្រែសភាពដីដោយការដាក់ជីកំបោរស ព្រោះវានិងជួយកែប្រែធាតុអាហារក្នុងដីសមស្របជាង ។ ហើយពេលដែលមានសភាពកំបោច្រើនក្នុងករណីដែលប្រើកំបោរសកែប្រែជាតិអាស៊ីដបានជាថ្មី ។ បើមិនបានទទួលពាក្យណែនាំពីអ្នកវិភាគនោះយើងបានបង្ហំការលូតលាស់របស់ដើមខ្នុរតាំងពីចាប់ដាំរហូត អាយុបីឆ្នាំ ។ លុះចូលឆ្នាំទី 4 ត្រូវប្រើជីដែលមានធាតុហ្វូសហ្វ័រ និងជួយបង្ហំនូវការចេញផ្កាឆ្នាំទី 4 បន្ទាប់ពីនោះត្រូវប្រើជីហ្វូសស្វាតរាល់ 2 - 3 ឆ្នាំម្តង ។

ធាតុស្ពាស់ធ័រ

ទោះបីមិនមែនជាធាតុទោល តែក៏មានការសំខាន់ណាស់សំរាប់ឈើផ្លែច្រើនប្រភេទដូចជា ៖ ធូរេន ខ្នុរក៏ត្រូវការធាតុនេះដែរ ។ ធាតុនេះអាច ជួយបន្ថែមចំណែកដែលបាត់បង់របស់រុក្ខជាតិ ព្រោះស្ពាន់ធ័រមានចំណែកផលិតកោសិការដើមឈើ ឡើងមកជាថ្មីជួយបង្កើត ខ្លូរហ្វីលសំរាប់រុក្ខជាតិកាលណារុក្ខជាតិខ្វះស្ពាន់ធ័រ ស្លឹកនិងតូចជាងធម្មតាស្លឹកខ្ចីលឿង ព្រំលែតខណៈនោះសសៃស្លឹកនៅខៀវធម្មតា ស្លឹកខ្ចីលឿងប្រែមុនគេក្លាយជាស្លឹកចាស់ ការកាន់ផ្លែមិនល្អច្រើនកំពិតកំពៀវ ហើយមានរសជាតិមិនល្អ ធម្មតាធាតុស្ពាន់ធ័រមានស្រេចហើយនៅក្នុងវត្ថុសេរីរាង្គ និងជីគីមី ដែលមានចំណែកផ្សំរបស់ស៊ុលហ្វាត ដូចជាជី អាម៉ូនីញាក់ស៊ុលហ្វាត ឬ ជីប៉ូតាស្យូមស៊ុលហ្វាត ( 0-0-50 ) ឬជី 49-9-20 ឬ 15-15-15 ឬ ឬ 14-14-21 ឬ 16-16-16 ទាំងនេះច្រើនមានស៊ុលហ្វាតស្រេចហើយ និងការប្រើវត្ថុសេរីរាង្គអត្រាមួយតោនក្នុងមួយហិចតាអែងបានធាតុស្ពាន់ធ័រយ៉ាងលើសលុបចំពោះខ្នុរ ។

## ធាតុប៉ូតាស្យូម

មុខងារធាតុនេះដូចបានរៀបរាប់ ។ ហើយដូចគ្នាក្នុងសៀវភៅផ្សេងៗថាមានមុខងារដែលជាបដិបក្ស ធាតុនីត្រូសែន បើខ្នុរស្មោកស្មឹក ។ ព្រោះបានទទួលទឹកនិងជីនីត្រូសែនច្រើនពេក កាលណាដាក់ជីដែលមានធាតុប៉ូតាស្យូមរមែងបន្ថយមុខងារធាតុប៉ូតាស្យូមចុះបាន ទើបគាំទ្រអោយដើមឈើសំរាកបានល្អឡើង ។ ដើម្បីត្រៀមខ្លួនមុនចេញផ្កា តែធាតុប៉ូតាស្យូមមានផលប្រយោជន៍តិចណាស់ ។ បើដីខ្វះធាតុប៉ូតាស្យូនោះធាតុនីត្រូសែនជួយគាំទ្រការធ្វើការងាររបស់ប៉ូតាស្យូមជានិច្ច ជីប៉ូតាស្យូមដែលត្រូវប្រើគឺជាប៉ូតាស្យូមនីត្រាត (13-0-46) កាលណាដែលសភាពដីមានសំណើម ខ្ពស់ និងមានធាតុនីត្រូសែនខ្ពស់រមែងត្រូវការធាតុប៉ូតាស្យូមច្រើនឡើង តែបើសភាពដីស្ងួតខ្លាំង សំណើមតិចរិតតែត្រូវការធាតុប៉ូតាស្យូមតិចចុះ ឬស្ទើរមិនត្រូវប្រើសោះក៏បាន ព្រោះបើអាកាសក្តៅដីស្ងួតកាលណាយើងប្រើធាតុ ប៉ូតាស្យូមរិតតែធ្វើអោយដើមរុក្ខជាតិ "ខ្នុរ" ខ្វះទឹកឆាប់ឡើងអាចធ្វើអោយមានការស្ទះការល្ងួតលាស់របស់ដើមឈើ រឿងនេះត្រូវប្រយ័ត្នហើយគួរពិចារណាពីសភាពបរិយាកាសមុនប្រើ ។

ធាតុប៉ូតាស្យូម និងស្ពាន់ធ័រមានចំណែកជួយអោយសាច់ក្លែបខ្នុរមានគុណភាពល្អ ផ្អែមស្រួយច្រើនជាង ក្នុងមធ្យាបាយផ្ទុយគ្នា បើផ្លែខ្នុរបានទទួលទឹកនិងធាតុនីត្រូសែនច្រើន សាច់ក្លែបផ្អែមថយចុះនិងសាច់ច្រើនហើយស៊ីមិនឆ្ងាញ់ ។ ដោយហេតុនេះមុនប្រមូល ផលខ្នុរទើបត្រូវឈប់ស្រោចទឹកយ៉ាងតិច 10 ថ្ងៃ គឺកំឡុងដែលត្រូវផ្តល់ខ្នុរបានរីកធំពេញទី ត្រូវផ្តល់ទឹកនិងជីនីត្រូសែន តែពេលផ្លែធំរីកពេញទីហើយត្រូវបញ្ឈប់ទឹក និងជីនីត្រូសែន ហើយអោយបន្ថែមធាតុប៉ូតាស្យូមដើម្បីទៅបំរុងសាច់ផ្លែ (ប្តូរម្សៅជាពណ៌ខ្មោត) ជាតិផ្អែមក៏ប្រសើរឡើងនិងសាច់ណែនស្រួយឆ្ងាញ់ ។

# 10. ការថែរក្សាខ្នុរមុនពេលផ្តល់ផល

កាលណាយើងដាំខ្នុររួចហើយដោយដាំពីមែកត ឬភ្ជាប់ភ្នែកក៏ដោយ បើមិនមានការថែរក្សាយកចិត្តទុកដាក់ទេនោះគង់មានការលូតលាស់ទៅតាមធម្មជាតិ គ្រាន់តែមិនគ្រប់គ្រាន់ទឹករហូតដីបែកក្រហែងតែវាលូតលាស់បាន ។

ពូជខ្នុរដែលដាំពីមែកត បើមានមែកខ្មែងបែកច្រើនមែក ។ ហើយជាមែកល្អដែលមានបង្គារធំសមគួរយើងក៏ទុកអោយមែកទាំងនោះដុះលូតលាស់ដោយធម្មតា ។ តែបើបែកពូជមានតែមួយមែកចាំបាច់ត្រូវក្តិចត្រួយចេញ កាលណាមែកពូជដែលដាំបានកំពស់ប្រមាណ 70-100 សង្ទីម៉ែត្រ ពេលនោះក្តិចត្រួយស្រួយចេញ ។ បន្ទាប់ពីនោះក៏បែកមែកខាងចេញមកក្នុងលំដាប់ទាបរបស់ផ្នែកត្រួយដែលក្តិច បើបែកមែកខាងច្រើនអោយជ្រើសរើសត្រឹមតែ 3-4 មែកប៉ុណ្ណោះ ។ យកចំពោះមែកដែលបែកមានបង្គាបធំ និងតំណាងរបស់មែកនិមួយៗមិនត្រួតលើគ្នា ។

ការស្រោចទឹកខ្នុរដើមតូច បើជារដូវភ្លៀងពុំចាំបាច់ស្រោចទឹកសោះ លើកលែងកំឡុងពេលដែលភ្លៀងរាំង ឬគ្មានភ្លៀង ត្រូវស្រោចទឹកអោយខ្លះ ចំណែករដូវប្រាំងបើស្រោចទឹកអោយខ្នុរបានរឹតតែធ្វើអោយខ្នុរលូតលាស់លឿនឡើង រឹតស្ទុះទៅក្នុងរដូវប្រាំងបញ្ចេញផល អោយដើមនោះចេញផ្លែបានលឿនឡើង អាចកាន់ផ្លែក្នុងឆ្នាំទី 3 ហើយចំណែកជីគីមីគួរប្រើគួបនិងជីផ្ទាប់ដីក្រោល ហើយជីដែលមានធាតុនីត្រូសែនខ្ពស់ដូចជា 20-11-11 ឬជីដែលប្រហាក់ប្រហែលគ្នាតាមធម្មតា ។ ជីគីមីនិងផ្តើមអោយខ្នុរបន្តពេលក្រោយខ្នុរដាំរួចនិងតាំងជំហរអោយជាប់ ហើយនិងមានការបែកត្រួយថ្មីយ៉ាងតិចមួយដងក្នុងកំឡុងឆ្នាំទី 1-2 អាចប្រើធាតុផ្សំស្មើដូចជា 15-15-15 ឆ្លាស់និងជីអ៊ុយរ៉េ តែពេលដុតអាយុពីរឆ្នាំទៅហើយអោយឈប់ប្រើជីអ៊ុយរ៉េ ក្រៅពីបណ្តាលអោយស្លឹកខ្នុរស្មោកបញ្ចេញផលអោយខ្នុរដើមនោះផ្តើមចេញផ្លែយឺតយាវទៅបាន ។

ការបង្ហំការលូតលាស់ ខ្នុរក្នុងមួយឆ្នាំដំបូង យើងអាចប្រើជីគីមីគ្រប់ៗខែដោយប្រើមួយខែមួយខាំ ហើយបាចអោយផុតពីគល់មួយហ្វុត ឬ បរិមាណជុំវិញគល់ បើភ្លៀងមិនធ្លាក់ត្រូវការស្រោចទឹករាល់ពេលដាក់ជី (កុំស្រោចទឹកច្រើនពេក ទឹកនិងនាំជីចេញ) ជីផ្ទាប់ជីក្រោល បើរកដាក់ខ្នុរបានគួរដាក់អោយរាល់ៗខែមួយខែ ឬកន្លះខែ មួយបង្គីនិងជួយអោយដើមធំលឿន ។

ដើមខ្នុរដែលមានអាយុលើសពីពីរឆ្នាំកន្លះទៅហើយសង្កេតឃើញថា ល្អហួសទល់តែស្លឹកស្លោកមកពីបានទទួលជីផ្ទាប់ និងជីក្រោល ឬ ជីនីត្រូសែន ច្រើនពេកត្រូវផ្តើមដាក់ជីដែលមានធាតុប៉ូតាស្យូមដូចជា 14-9-20 ដើម្បីបន្ថយការស្លោកស្លឹក ហើយត្រូវការខ្នុរផ្តើមចេញផ្លែតាមកំណត់ក្នុងកំឡុងឆ្នាំទី 3 ដល់ឆ្នាំទី 4 ។

ខ្នុរដែលចាប់ផ្តើមដាំពីមែកតនិងមែកភ្ជាប់ភ្នែកត្រូវខំសង្កេតមើលបរិមាណគល់ ឬដើមត “គល់” កុំអោយមានខ្នែងពន្លកដុះឡើងបាន បើឃើញមានត្រូវប្រញាប់ក្តិចចោលភ្លាម ។

ចំណែករឿងស្មៅនោះត្រូវសំអាតដោយព្យាយាមកាត់ស្មៅជុំវិញគល់ អោយខ្លីហើយយកស្មៅដែលកាត់នោះទៅដាក់ជុំវិញគល់ទុក លុះស្មៅខ្ពស់ក៏កាត់ខ្លីទៀតរបៀបនេះជួយអោយដីល្អឡើង ។

ដើមខ្នុរដែលពុំទាន់ផ្តល់ផល យើងមិនត្រូវទៅបន្តពូជដើមនោះទេ (បើគិតយកផ្លែ) បើមិនដូច្នោះនិងធ្វើអោយការចេញផ្លែយឺតយ៉ាវតទៅច្រើនឆ្នាំទៀត ខ្នុរដើមតូចពុំមានជង្គរចោះឡើយ តែច្រើនប្រទះពួកខ្នង ប្រមោយ សត្វល្អិត ខាំស៊ីស្លឹកចាស់ខ្លះ ហើយនិងចៃម្សៅ បំផ្លាញស្លឹកខ្ចីត្រួយខ្ចីខ្លះ ( អានអំពីរឿងសត្រូវរបស់ខ្នុរ )

ដើមខ្នុរអាយុបានមួយឆ្នាំឡើងទៅធ្វើការកាត់តែងមែកអោយបានសមរម្យ អោយបានស្រឡះខាងក្នុងដើម្បីអោយពន្លឺចូលបាន ត្រូវជ្រើសទុកចំពោះមែកទោលធំ បើប្រទះមែកអំពង់បែកចេញមកនៅលើមែកធំនោះត្រូវកាត់ចេញដូចបានរៀបរាប់ក្នុងរឿងកាត់តែងមែក ។

# 11. ខ្នុរចាប់ផ្តើមផ្តល់ផល

ដូចបានជ្រាបមកហើយថាខ្នុរ ជាឈើដើមធំខ្នាតផ្លែក៏ចាត់ថាជាធំបំផុតដែរ ការចេញផ្លែត្រូវចេញពីដើមឬមែកធំប៉ុណ្ណោះ ឬបើចេញផ្លែពីមែកតូចមិនសូវល្អ តែទូទៅពុំចេញផ្លែតាមមែកតូចទេ ហើយពុំមានប្រទះឃើញសោះថាចេញផ្លែឯចុងមែក ។

ក្រុមឈើផ្លែដែលចេញផ្លែតាមគល់ ឬមែកធំបានដឹងច្បាស់ថាមាន ស្មៀវ ឡាងសាត ចំណែកដែលចេញផ្លែតាមមែកដូចជា ធូរេន ។

ការចេញផ្លែរបស់ឡាងសាត ឬសូម្បីតែធូរេនក៏ចេញផ្កា ឃើញថាវាទម្លាក់ទងផ្កាពីមែកដោយផ្ទាល់ចេញមកជាទងផ្កាភ្លាមតែចំពោះ ខ្នុរពុំមែន ទម្លាក់ទងផ្កាពីគល់ គល់មែកទេ ចំពោះស្មៀវឡាងសាតដុះទងផ្កាបានពីពន្លករបស់ទងផ្កា ហើយពេលទម្លាក់ទងផ្កាចេញមក រហូតដល់រដូវកាលចេញផ្កា ។

ខ្នុរពុំមែនចេញផ្កាពីគល់ដោយផ្ទាល់ទេ តែទម្លាប់ទងផ្កាជាត្រួយខ្ចីប្រហាក់ប្រហែលនិងកើតជាមែកអំពង់ចេញមកមុនហើយនិងដុះជាផ្កាមកតាមក្រោយ ឬក្នុងពេលដែលគៀកគ្នា បើនិយាយអោយត្រឹមត្រូវទៅខ្នុរពុំបានចេញទងផ្កាពីមែកគល់ ឬគល់មែកដោយផ្ទាល់ទេ តែប្រទះឃើញថាខ្នុរចេញផ្កាដោយមានកើតត្រួយខ្ចីមុន គ្រាន់តែពុំមាននរណាចែកការកើតផ្ការបស់ខ្នុរទុក ឬហៅការកើតផ្ការបស់ខ្នុរថាកើតពីមែក ឬដើមច្បាស់ទេ ។ តែយើងឃើញថាខ្នុរជាប់ផ្លែតាមដើម ហើយមែកខ្នុរដែលបែកតាមគល់ដើមទាំងការដុះផ្កានោះហៅថាអ្វី ? គឺចំណែកដែលនៅជាប់និងទងផ្លែនោះពេលដំបូងហៅថាអ្វី ? តែដល់ជាប់ផ្លែ ហើយយើងហៅរូមថាទងរបស់ផ្លែ ។

ដោយហេតុនេះទើបមិនដឹងថាខ្នុរចេញផ្កាតាមដើម ឬចេញផ្កានៅត្រួយដែលបែកចេញមកតាមគល់ដើមច្បាស់ ព្រោះពុំមែនចេញផ្កាពីផ្នែករបស់ដើមដោយផ្ទាល់ទេ បើនិងហៅថាខ្នុរកើតពីមែកអំពង់ឯគល់ដើមក៏មិនមែន ។ សូមប្រាប់អោយអ្នកបច្ចេកទេសជួយស្រាវជ្រាវអោយផង

ព្រោះការដែលសង្កេតឃើញមកវាដូច្នោះមែន ស្វាយ៉ារីតែខ្នុរមានអាយុ ក្រោយពីដាំបាន 2-3 ឆ្នាំក៏ចេញផ្កាបានដូចគ្នាតែមិនសូវកាន់ផ្លែអាចកើតជាផ្កាឈ្មោល ហើយផ្កានេះចេញអោយឃើញលើកដំបូងក៏ពុំមែនពីគល់ ឬមែកដោយផ្ទាល់តែរួមទាំងភ្នែកផ្ការបស់ខ្នុរ នៅត្រង់ចំណុចណាច្បាស់នៅត្រង់ថ្នែករបស់ដើម ឬថ្នែកផ្កានៅបរិវេណត្រួយដែលបែកចេញមកថ្មី ។

កាលណាលាស់ត្រួយថ្នែកគល់ដើម ត្រួយនោះមានស្លឹកស្មើរគ្រប់ថ្នាំង ហើយផ្កាខ្នុរនិងដុះនៅបរិវេណថ្នាំងទីមួយទៅថ្នាំងទី 7 ឬផ្កា ខ្លះទៅដុះនៅត្រង់ថ្នាំងចុងបង្អស់ក៏មានតែជាទូទៅច្រើនចេញផ្កាត្រង់ថ្នាំងទី 3 - 4 ហើយអាចដុះផ្កាក្នុងថ្នាំងមួយច្រើនផ្កាក៏មាន ។ ចំពោះខ្នុរចង្កោមមានទៅដល់ 4 ផ្កាក្នុងមួយថ្នាំងៗ តែការលាស់ត្រួយដើម្បីលាស់ចេញផ្កាតាមគល់ដើម ឬតាមមែកក៏ពុំមានន័យថាលាស់ត្រួយឡើយ ត្រូវចេញផ្កាអោយគ្រប់ពេលសិន ហើយត្រួយដែលបែកថ្មីនេះបើមិនចេញផ្កាហើយភាគច្រើនមិនអាចស្លាបនា ឬប្រួតហោស់មៅជាបែកបានមេ ដែលខុសថ្នែកពីការបែកមែកអំពង់របស់ឈើផ្លែផ្សេងៗ ។ ដូច្នោះសរុបបានថាខ្នែងដែលបែកចេញតាមគល់ដើម (ពមកចេញផ្កាផ្លែ) នោះពុំមែនថ្នែកដែលជាមែកអំពង់ទេ ។ តាមលក្ខណៈពេលបែកចេញមកដើម្បីការចេញផ្កា តែបើពុំអាចចេញបានដោយហេតុផលណាក៏ដោយ ថ្នែកនោះមិនអាចស្លាបនាទៅជាមែកបានទេ ។

អំពីនិស្ស័យការចេញផ្ការបស់ខ្នុរដូចរៀបរាប់ មានមនុស្សជាច្រើនជឿថាពន្លឺថ្ងៃមានចំណែកមួយជួយអោយដុះថ្នែកដែលក្លាយជាត្រួយខ្ចីតាមគល់ ដើមឬគល់មែក ទើបមានការកាត់តែងមែកខ្នុរអោយស្រឡះបន្តិច ដើម្បីអោយពន្លឺថ្ងៃចាំងចូលបានសព្វបរិវេណគល់ដើម មានការធ្វើរស្មីសំយោគពន្លឺដាស់អោយដុះពន្លកបរិវេណគល់ដើម ហើយដុះផ្កាមកតាមក្រោយដែលប្រទះថាដើមខ្នុរដែលស្រឡះមានពន្លឺថ្ងៃចាំងដល់គល់ដើមបានខ្លះនោះ ចេញផ្កាកាន់ផ្លែបានល្អជាងដើមខ្នុរដែលមានដើមណែនស្អុកពន្លឺថ្ងៃចូលមិនដល់គល់ដើម រឿងនេះគ្រាន់តែជាការសង្កេត ចំណែកហេតុផលខាងបច្ចេកទេសត្រូវអោយអ្នកបច្ចេកទេសគេអោយចម្លើយម្តងទៀត ។

ខ្នុរជាឈើផ្លែដែលផ្កាកេសរឈ្មោល និងកេសរញី នៅក្នុងដើមតែមួយ តែចែកគ្នានៅម្នាក់មួយផ្កាដរាបណាផ្កាញីពុំបានទទួលការផ្សំពីលំអងកេសរឈ្មោល ខ្នុរផ្កានោះរមែងមិនជាប់ផ្លែឡើយ ។

ផ្កាឈ្មោលរបស់ខ្នុរដែលហៅថា "ឈ្មោល" នោះកាលណាផ្តើមចេញផ្កាលក្ខណៈប្រហាក់ប្រហែលនិងផ្កាញី គ្រាន់តែផ្កាញីនោះមានបន្លាមើលឃើញច្បាស់ " មេ " ។ ឈ្មោលមានបន្លាមិនច្បាស់ដូចផ្កាញីទេ កាលណាផ្កាឈ្មោលផ្តើមបញ្ចេញក្លិនស្អែងថាព្រមនិងផ្សំបានតែដោយសារការផ្សេងគ្នាទើបត្រូវអាស្រ័យសត្វល្អិតជួយ ដោយហេតុនេះឃ្មុំនិងសត្វល្អិតរុយគង់មានមុខនាទីសំខាន់ដល់ការផ្សំកេសរ ។ ធ្លាប់មានចំការច្រើនប្រទះឃើញថាយកសាកសពទៅដាក់ទុកក្នុងបរិវេណគល់ដើមជួយអោយខ្នុរនោះកាន់ផ្លែល្អ អាចគិតទៅថាសាកសពសព្វនោះគឺជួយអោយកើតការចេញផ្លែផ្កាល្អឡើងតែតាមពិតសាកសពជាប្រភពបណ្តុះបណ្តាលរុយ កាលណាមានរុយច្រើនរមែងមានឱកាសច្រើនដល់ការផ្សំកេសរ ដោយសង្ឃឹមអោយឃ្មុំជួយផ្សំកេសរនោះបច្ចុប្បន្នសង្ឃឹមបានតិចព្រោះត្រូវថ្នាំគីមីច្រើនប្រភេទបំផ្លាញសត្វឃ្មុំយ៉ាងខ្លាំង គួរមានការបណ្តុះបណ្តាលរុយ ។ កាលណាខ្នុរផ្តើមចេញផ្កាអាចនាំសាកសពសត្វឬអាចមិសត្វថ្មីៗទៅដាក់គរទុកព្រោះជាប្រភពបង្កើតរុយបានល្អ ។ តែយ៉ាងណាក៏ដោយខ្នុរចេញផ្កាបានច្រើនលើកជាប់គ្នាលើកក្រោយដែលមានផ្កាឈ្មោលគ្រប់គ្រាន់រមែងផ្លែល្អជាងលើកខ្លះដែលមិនសូវមានផ្កាឈ្មោល ។

ខ្នុរមានសត្រូវបំផ្លាញខ្លះដូចជាពពួកមេរោគផ្សេងៗ រឿងនេះត្រូវជួយកំចាត់ផ្សិតផង ដោយការពារបាញ់ថ្នាំកំចាត់មេផ្សិតកំឡុងចាប់ផ្តើមផ្កាឈ្មោលជាប់ផ្លែខ្ចី ។ ហើយបើខ្វះទឹកត្រូវជួយស្រោចទឹកខ្លះតាមការពិនិត្យឃើញ កុំបណ្តោយអោយដើមខ្នុរខ្វះទឹកក្នុងពេលដែលមានផ្លែខ្ចី បើពុំដូច្នោះទេនិងល្វតលោសពុំបានល្អឡើយ ។

ផ្លែខ្នុរខ្ចីដែលជាប់ច្រើនពេកអាចកាត់ចេញខ្លះ តែជាទូទៅយើងជួយអោយផ្លែខ្ចីទាំងអស់ធំល្មមមុននិងកាត់ចេញដោយហេតុផលថាផ្លែខ្ចីដែលកាត់ចេញនោះអាចយកទៅបរិភោគបាន ឬលក់ជាខ្នុរសម្លរបាន ឬក៏អាចជ្រើសរើសទុកផ្លែដែលល្អបានស្រួលជាងការជាប់ផ្លែតិចពេក បើប្រទះឃើញថាទងផ្លែនិមួយៗជាប់ផ្លែលើសពីពីរត្រូវកាត់ចេញ តែបើមានការពង្រីកជាប់ផ្លែបានល្មមគួរទុកអោយផ្លែមួយជាការល្អ ព្រោះនិងបានផ្លែដែលមានខ្នាតធំល្អ ផ្លែដែលត្រូវកាត់ចេញខ្លះដូចជាផ្លែដែលផ្សំជាប់មិនល្អ គឺទ្រង់ទ្រាយផ្លែកំពិតកំញេវ ឬផ្លែដែលជាប់នៅក្នុងថ្នាំងតែមួយច្រើនពេកត្រូវជ្រើសរើសផ្លែល្អទុកត្រឹមតែមួយឬពីរផ្លែប៉ុណ្ណោះ លើកលែងតែខ្នុរចង្កោមដែលអាចទុកបាន

មួយទងមានផ្លែ 4-5 ផ្លែ ក្រៅពីនេះផ្លែដែលជាប់នៅតាមមែកលើៗ ឬមែកតូចៗត្រូវកាត់ចេញ ។



# 12. កត្តាចង្រៃលើដំណាំខ្នុរ

បើយើងនិយាយថាខ្នុរពុំមានសត្រូវបំផ្លាញក៏មិនបាន ព្រោះតាមពិតបញ្ហាសត្រូវបំផ្លាញខ្នុរមានមិនតិចដូចគ្នា តែដោយហេតុសត្រូវខ្នុរមួយប្រភេទៗស្ទើរពុំមានជាបញ្ហាធំ បើយើងមិនបណ្តោយតាំងពីដំបូងការពារកំចាត់សត្រូវរបស់ខ្នុរពុំមែនថាត្រូវពឹងលើថ្នាំគីមីតែម្យ៉ាងទេ ទោះបីតែប្រើថ្នាំគីមីរួមផ្សំក៏បានត្រឹមតែចំពោះចំណុចដែលនបានបាញ់ មិនដូចនិងរុក្ខជាតិដទៃទៀតទេ ។ សត្រូវខ្នុរដែលសំខាន់គឺ ដង្កូវចោះដើម សត្វល្អិតចោះផ្លែ ដង្កូវស៊ីស្លឹក និង មេរោគផ្សិត ។

ដង្កូវចោះមែក និងដើម

ខ្នុរដែលបណ្តោយអោយលូតលាស់តាមធម្មជាតិ ឬដើមខ្នុរដែលមានឡើងជាទូទៅតែពុំបានយកចិត្តទុកដាក់ ទើបជួបប្រទះបញ្ហាដង្កូវចោះដើមជានិច្ច ដោយប្រភពបណ្តាលមកពីទឹកភ្លៀងធ្លាក់ញឹកញាប់ពេក ។

ដង្កូវចោះដើមកើតពីសត្វល្អិតប្រភេទខ្លះមកពងដាក់លើមែកខ្នុរ លុះពងញាស់ជាដង្កូវវាចោះខែចូលបំផ្លាញខាងក្នុងដើមមែកធ្វើអោយស្ងួតងាប់បាន ដង្កូវចោះមែកនិងដើមចូលបំផ្លាញដើមខ្នុរច្រើននៅរដូវភ្លៀងចំពោះដើមខ្នុរដែលមានដើមណែនក្រាស់ពេក ហើយបណ្តាលអោយមែកស្ងួតរាលពេញដើម ។

<u>ការពារនិងកំចាត់</u>

1. ត្រូវកាត់តែងខ្លះ កុំអោយណែនពេកចំពោះមែកស្ងួតត្រូវកាត់ចេញ លុះកាត់ដើមហើយយកប្រេងលាបមុខកាត់ ។
2. ប្រើប្រេងលាបតាមដើម ព្រោះប្រេងជួយមិនអោយសត្វល្អិតមកពងដាក់បាន ។
3. បំផ្លាញដង្កូវធំៗ (មេអំបៅ) មុនពេលពងញាស់ជាដង្កូវ ។

4. ប្រើថ្នាំគីមីពពួក មេថាមិដូហ្វស ឈ្មោះជំនួញហៅថា ថាមារ៉ុន ដោយប្រើបាញ់ចូលទៅនៅពេលល្ងាច ពេលព្រលប់ដង្កូវរើបំភាស់ហើយនិងងាប់នៅក្នុងរន្ធ ។

## ដង្កូវនិងសត្វល្អិតចោះដើម

មានឈ្មោះខាងវិទ្យាសាស្ត្រ Bactrocera umbrosa Fabr ចូលបំផ្លាញរុក្ខជាតិត្រកូលផ្ចុចជាខ្នុរស្ទើរគ្រប់ប្រភេទកើតពីសត្វល្អិតមកពងដាក់លើផ្លែរបស់ខ្នុរ ពងញាស់ជាដង្កូវពណ៌សវែងប្រហែលមួយសង់ទីម៉ែត្រ ហើយចូលទៅបំផ្លាញផ្លែខ្នុរបន្ទាប់ពីនោះនិងទម្លាក់ខ្លួនចុះដីក្លាយជាឌុកឌឿក្នុងដី វដ្តជីវិតរបស់ដង្កូវពួកនេះប្រហែល 21 ថ្ងៃ ។

សត្វដែលសំខាន់ចូលបំផ្លាញផ្លែខ្នុរចំពោះប្រភេទខ្លះ ផ្លែខ្នុរត្រូវបំផ្លាញដោយដង្កូវចោះផ្លែស្ទើរទាំងដើមក៏មានផ្លែខ្លះដែលត្រូវបំផ្លាញបន្ត បន្ទាប់ច្រើនជ្រុះឬមិនជ្រុះក៏បែកជារលួយ ។

ការដោះស្រាយបញ្ហាដង្កូវចោះផ្លែខ្នុរនោះមិនលំបាក គ្រាន់តែប្រើក្រដាសកាសែត ឬថង់ក្រដាស់ (ការុងចំណីសត្វ ឬ ការុងស៊ីម៉ង់ត៍) ខ្ចប់ផ្លែខ្នុរ នៅមិនទាន់ចាស់ គួរខ្ចប់មុនពេលបន្លាផ្លែរីកធ្លាយ ឬកេះមើលថាផ្លែខ្នុរធំបាន 2/3 របស់ផ្លែដែលធំពេញទីហើយ ទើបធ្វើការខ្ចប់ផ្លែ ។

ការខ្ចប់ផ្លែដោយក្រដាស់អាចការពាររោគ និងសត្វល្អិតបានស្ទើរគ្រប់ប្រភេទចំរាំនិងបេះផ្លែដោយខ្នុរជាផ្លែឈើដែលមានខ្នាតធំចាំបាច់ ត្រូវប្រើថង់ក្រដាសដែលធំល្មមដល់ការពង្រីករបស់ផ្លែខ្នុរតមកទំរាំនៅពេលបេះហើយការខ្ចប់ខ្នុរពុំមែនជារឿងមិនទាន់បច្ចេកវិទ្យា តែជាវិធីដ៏ល្អបំផុត សូម្បីតែក្នុងប្រទេសហ្វីលីពីនក៏ព្រមទទួលថាការខ្ចប់ខ្នុរដោយក្រដាស់ជាវត្ថុចាំបាច់ (The Philippine Journal of Agriculture Vol. 14, No. 3) ហើយខ្នុរមួយដើមៗមិនលើសពី 50 ផ្លែទេ ដូម្តេចខ្ចប់ខ្នុរមិនបាន ។

ធ្លាប់មានការពិសោធន៍ខ្ចប់ផ្លែខ្នុរដែលត្រូវដង្កូវចោះផ្លែ ហើយប្រទះឃើញថាមានពពួកស្រមោចខ្មៅចូលទៅធ្វើសំបុកក្នុងថង់ក្រដាស់ដែលបានខ្ចប់ ហើយធ្វើអោយផ្លែខ្នុរនោះចាស់ទុំបានមិនជ្រុះ

រុយរំផ្លាញផ្លែឈើ *(Bactrocera dorsalis)*




Source: Ahmad Yunus and A. Balasubramaniam, Major Crop Pests in Peninsular Malaysia (Kuala Lumpur: Ministry of Agriculture, 1981) as reproduced in Othman Yaacob and Suranant Subhadrabandhu, The Production of Economic Fruits in South-East Asia (Kuala Lumpur: Oxford University Press, 1995), 296.

ទាំងនេះស្រមោចខ្មៅចូលធ្វើសំបុក ហើយខាំស៊ីផ្នែកដែលរលួយ ហើយខាំស៊ីបំផ្លាញដង្កូវផង ទើបធ្វើអោយកន្លែងរលួយសះមិនរាលដាលទំរាំផ្លែទុំនៅសល់ស្នាមបែកធម្មតា ។ ដូច្នេះពេលជួបប្រទះផ្លែខ្នុរដែលត្រូវបំផ្លាញដូចលក្ខណៈនេះត្រូវប្រញាប់ខ្ចប់ផ្លែខ្នុរភ្លាម កាលណាស្រមោចខ្មៅចូលទៅធ្វើសំបុកជាមួយសត្វឯទៀតអាចបំផ្លាញដង្កូវ និងជួយធ្វើការសំអាតកន្លែងរលួយបាន ហើយផ្លែខ្នុរនោះអាចចាស់ ទុំ បរិភោគបាន ។

ករណីដែលក្រដាស់ខ្ចប់ផ្លែត្រូវខ្យល់ភ្លៀងអាចរហែកដាច់បាន ក៏ត្រូវធ្វើការខ្ចប់ផ្លែជាថ្មីក្នុងពេល 2-3 ថ្ងៃតែភាគច្រើនបើថង់ក្រដាស់អាហារសត្វ ឬក្រដាសស៊ីម៉ង់តិច្រើននៅរហូតដល់បេះផ្លែដោយមិនរហែកដាច់ឡើយ ។

## សត្វល្អិតខាំស្លឹកស៊ី

ជាទូទៅស្លឹកខ្នុរត្រូវបំផ្លាញតិចច្រើន បណ្តាលមកពីមានការដាំខ្នុរតែម្យ៉ាងក្នុងផ្ទៃដីទូលាយ សត្វល្អិតដែលបំផ្លាញស្លឹករុក្ខជាតិផ្សេងៗច្រើនជាង បំផ្លាញស្លឹកខ្នុរ ។

សត្វល្អិតដែលខាំស៊ីស្លឹកខ្នុរ ដូចជាអណ្តើកមាស ឬឌុង ជាសត្វដែលយើងច្រើនឃើញវាឡើងជិះគ្នាឯង ច្រើនប្រទះឃើញញីកញាប់នៅពេលព្រឹក ខ្នាតប្រវែល 1-1.50 សង្ទីម៉ែត្រ មានពណ៌ខ្មៅតែមើលឃើញជាពណ៌ខៀវខ្លះលឿងខ្លះ មកពីមានម្សៅពណ៌រុំ ហើយម្សៅពណ៌នេះចាំងពន្លឺទើបធ្វើអោយមើលឃើញថា ជាពណ៌ផ្សេងៗឆ្លាស់គ្នាកើតសត្វល្អិតដែលចូលចិត្តខាំស៊ីស្លឹកចាស់ជាប្រហោង ឬស្លឹកមានស្នាមបែកតែមិនបំផ្លាញស្លឹកខ្ចី ។

កូនដង្កូវកើតមកពីមេដង្កូវដាក់ពងតាមគំនរស្មៅ និងស្លឹកឈើដង្កូវខែចូលដីដើម្បីក្លាយជាឌុកខៀ ។ ការពារកំចាត់ប្រើថ្នាំគីមីពពួក ខាបារិន ដូចជា សេវិន 85, ផែស 85 ឬ ខាប៉ុរេណេក ក្រៅពីនេះគួរសំអាតបរិវេណគល់ដើមដើម្បីការពារមិនអោយដង្កូវក្លាយជាឌុកខៀ ។

## ពពួកចៃខ្យងនិងចៃម្សៅ

ខ្យងមានទាំងពួកដែលមានពណ៌ត្នោតឆែក មានស្រោមហ៊ុំខ្លួនរឹង ហើយពួកពណ៌សម្ទូលចាំជញ្ជាក់ស៊ីស្លឹករុក្ខជាតិដោយទុំលើស្លឹកជាក្រុមៗ ។

ចំណែកចៃម្សៅច្រើនបំផ្លាញត្រួយនិងស្លឹកខ្ចី ជញ្ជក់ស៊ីរុក្ខជាតិរស់ ធ្វើអោយស្លឹកងរកំពិតកំពៀវការបំផ្លាញរបស់ចៃម្សៅមើលឃើញបានច្បាស់ ឯស្លឹកខ្ចីហើយនិងត្រួយខ្ចីឃើញជាក្រុមពណ៌ស តាមលើស្លឹកខ្ចី និងធាងស្លឹកដែលទើបបែកថ្មីហើយមើលពីខាងខ្នង (ខាងលើស្លឹក) ត្រង់កន្លែងដែលចៃបានទុំបំផ្លាញ (លើស្លឹក) ឃើញមានពណ៌ខៀវលាយលឿងឬពណ៌ព្រលេតជាងស្លឹកធម្មតា ។

កំពោះអែកពួជន្លរឬត្រួយខ្ចី ពីដើរដែលភ្ញាប់ភ្ញែកឬប្តូរត្រួយ ត្រូវបានតាមដានការបំផ្លាញរបស់ចៃអោយល្អ បើពុំដូច្នោះនិងធ្វើអោយស្លឹកខ្ចី និង ត្រួយខ្ចីដែលទើបបែកថ្មីត្រូវបំផ្លាញបានយ៉ាងងាយឬជាស្លឹកដែលមិនល្អផ្តល់ផលអោយស្ទះការបែកត្រួយ ។

ការកំចាត់ដោយប្រើថ្នាំគីមីពពួកខាបារិន បាញ់ចំពោះលើស្លឹកខ្ចីនិងតាមគល់ ហើយនិងទងត្រួយខ្ចី

## ជំងឺ

មានជំងឺផ្សិតនៅលើផ្កា ធ្វើអោយផ្កានិងផ្លែខ្ចីរលួយជាពណ៌ខ្មៅហើយជ្រុះ ការការពារត្រូវបាញ់ថ្នាំការពារផ្សិតផ្សេងៗ ឬ ស្ពាន់ធ័រប្រភេទរលាយទឹកបាន មួយប្រការទៀតដើមខ្នុរបានទទួលពន្លឺថ្ងៃដើមស្រឡះល្អ មានជំងឺបំផ្លាញតិច ការថែរក្សារកាត់តែងមែកទើបជាវត្ថុដែលគួរអនុវត្តនិខ្លះតាមសមគួរ ។

## ជំងឺឫសរលួយ

ជាជំងឺដ៏សំខាន់របស់ខ្នុរ ការពារគឺព្យាយាមកុំអោយមានទឹកដក់ ឫចៀសវាងការដាំខ្នុរក្នុងដីដែលមានលំដាប់ទឹកក្នុងទីទំនាប ។

ក្រៅពីនេះក៏មានជំងឺផ្សេងដែលកើតនិងស្លឹកមែកឫដើមខ្លះដែរ ។ តែមិនមានការខូចខាតខ្លាំងណាស់ណាទេត្រូវបានបំរុងរក្សាដើមអោយរឹងមាំ ធ្វើការសំអាតចំការជានិច្ចមិនបណ្តោយអោយស្មុក ព្រមទាំងមានការកាត់តែងមែកចេញខ្លះកុំអោយដើមណែនក្រាស់ពេក រហូតដល់កាត់តែងមែក ដែលកើតជំងឺ មែកដែលមិនស្ទូវល្អកាត់ចោលជានិច្ចជាការការពារការបំផ្លាញ ។

# 13. ការប្រមូលផល

ខ្នុរដើមខ្លះ ពូជខ្លះមានអាយុកាលការប្រមូលផលខុសប្លែកគ្នា ដូចជាពូជស្រាលសំបកផ្អែមចាប់ពីចេញផ្ការហូតប្រមូលផលបាននោះ មិនលើសបីខែ តែខ្នុរដើមខ្លះ ពូជខ្លះ ផ្លែខ្លះអាចអាយុដល់ 8 ខែក៏អាស្រ័យទៅលើពូជនិងសភាពបរិយាកាស ។

ខ្នុរនៅពេលខ្ចីមិនទាន់ចាស់ បន្លាផ្លែច្រើនញឹក ហើយបន្លាស្រួចពណ៌ខៀវតែពេលចាស់បន្លាឃ្លាតគ្នា ពណ៌របស់បន្លាផ្តើមប្តូរពណ៌ជា ពណ៌ខៀវ លឿងត្នោតទាំងនេះជាដើម ។

ផ្លែខ្នុរដែលចាស់អាចបេះបាន ដោយសង្កេតមើលភ្នែកបន្លាដែលដុះរីកឃ្លាតគ្នា ឬដោយការរាប់អាយុរបស់ផ្លែ ពីថ្ងៃដែលផ្សំជាប់រហូតផ្លែចាស់ ប្រហែល 8 ខែ នៅរដូវក្តៅខ្នុរនិងចាស់អាចបេះបានលឿនជាងរដូវភ្លៀង ហើយសម្បុរផ្លែខ្នុរមានពណ៌លឿងច្រើនជាង អាចប្រើកាំបិតចោះជិតទងផ្លែ បើផ្លែនោះជាផ្លែចាស់មានជ័រហូរចេញមកតិចៗហើយមានលក្ខណៈខាប់ស្អិត តែបើទឹកជ័រដែលហូរចេញមក ជាទឹកជ័រថ្លាៗស្តែងថាផ្លែនោះចាស់ល្មម ឬអាចសង្កេតស្លឹកចិញ្ចឹមដែលនៅជាប់និងទងផ្លែផ្លាស់ប្តូរជាពណ៌លឿងបញ្ជាក់អោយឃើញថាផ្លែចាស់ ។ ក្រៅពីនោះការផ្ទាត់ផ្លែបើមានសម្លេងស្រឡះក៏អាចធ្វើការបេះបាន ។ គល់ទងជិតផ្លែកុំទុកអោយទងវែងនិងធ្វើអោយទងដែលសល់រលួយ ការប្រមូលផលដែលនៅខ្ពស់ៗត្រូវកាត់ដាក់កន្ត្រកបង្ហូតចុះមកដើម្បីមិនអោយផ្លែខ្នុរជាំខូច ។

ផ្លែខ្នុរដែលបេះមកដោយមានទងវែង និងទុំយឺតជាងផ្លែខ្នុរដែលមានទងខ្លី ។ ពេលយកបន្ទុំត្រូវកាត់ទងផ្លែអោយជិតផ្លែទើបបន្ទុំទុំលឿន ។

ជាការសំខាន់មុនពេលបេះផ្លែត្រូវបង្អត់ទឹកយ៉ាងតិច 10 ថ្ងៃ អាចជួយអោយខ្នុរមានរស់ជាតិល្អឡើង ករណីដែលភ្លៀងនៅធ្លាក់គឺមានភ្លៀងដល់ថ្ងៃ ប្រមូលផលត្រូវប្រមូលផលកំណត់យ៉ាងតិច 5 ថ្ងៃ តែត្រូវច្បាស់ក្នុងចិត្តថាខ្នុរផ្លែនោះចាស់ហើយដើម្បីអោយទុំត្រូវរង់ចាំការបន្ទុំ 5-6 ថ្ងៃ ។

ផ្លែខ្នុរពេលកាត់ពីដើម បើនៅក្នុងលំដាប់ដែលដៃអាចឈោងបេះបាន ត្រូវព្យាយាមកាត់មកកុំអោយផ្លែធ្លាក់បុកដីបាន ឬបើជាផ្លែដែលនៅខ្ពស់ត្រូវប្រើខ្សែចងបង្ហូតចុះមកកុំកាត់អោយផ្លែធ្លាក់ដី សំបកផ្លែខ្នុរចាស់ដែលជាចំណុចចាប់ផ្តើមចូលទៅបំផ្លាញដោយមេរោគផ្សិតបានងាយ ។



# 14. ទីផ្សារ និងការប្រើប្រាស់ផលិតផលខ្នុរ

ការសំខាន់របស់ខ្នុរគឺផ្លែជាការសំខាន់ណាស់ ដើមខ្នុរជាឈើផ្លែពុំសូវមានតម្លៃណាស់ណាទេ សូម្បីតែពេលឥឡូវនេះតម្លៃខ្នុរក៏រាប់ថានៅក្នុងតម្លៃលំដាប់មធ្យម ឬកន្លែងខ្លះអាចទាបអាស្រ័យទៅលើការយកចិត្តទុកដាក់របស់អ្នកបរិភោគ និងគុណភាពរបស់ខ្នុរ ។ ជាការសំខាន់មកពីខ្នុរដែលដាំភាគច្រើនពុំបានជ្រើសរើសពូជប៉ុន្មានទេ រួមទាំងការមិនសូវយកចិត្តទុកដាក់លើដើមខ្នុរជាហេតុធ្វើអោយផលិតផលខ្នុរទាបជាង 80% ក្នុង ទីផ្សារជាខ្នុរកម្រិតទាប សាច់ផ្លែបស្អើង សាច់ផ្លែបមិនស្រួយពុំសូវផ្អែមល្អ ។

បច្ចុប្បន្នទីផ្សារធំរបស់ខ្នុរគឺក្រុងថេប Bangkok ករណីទីផ្សារលក់ដូរដែលសំខាន់គឺផ្សារមហានាគ ទីផ្សារស្ពានខាវ ខ្នុរទាំងនេះបាននាំ មកពីខេត្តផ្សេងៗដឹកនាំមកកាន់ទីផ្សារទាំងនេះយ៉ាងច្រើន បន្ទាប់ពីនេះអ្នកទិញបានទទួលទិញពីផ្សារដូចរៀបរាប់ខាងលើយកទៅពុះផ្លែបលក់តាមកន្លែងតាមផ្សារផ្សេងៗទូទៅក្នុង ក្រុងថេប ព្រោះពីកាល 2-3 ឆ្នាំដែលកន្លងផុតទៅខ្នុរកេះផ្លែបលក់មួយគីឡូក្រាម មិនទាបជាង 30 បាត គិតថាជាតម្លៃដែលសមគួរ ហើយខណៈនេះផ្សារខ្នុរដែលសំខាន់គឺនៅជាផ្សារខ្នុរដដែល តែទោះបីជាយ៉ាងណាក៏ដោយក៏រោងចក្រកែច្នៃផ្លែឈើមើលឃើញការសំខាន់របស់ខ្នុរ ក្នុងរូបភាពផ្សេងៗដូចជាខ្នុរកំប៉ុង ដំណាប់ខ្នុរ ឬសូម្បីតែខ្នុរបញ្ជូនចេញទៅលក់នៅប្រទេសក្រៅទីផ្សារ ទាំងនេះគាំទ្រអោយតម្លៃខ្នុរល្អជាងឈើផ្លែច្រើនប្រភេទទៀត ។



## ឯកសារយោង References

### *អត្ថបទដើម (ភាសាថៃ) Original Text (Thai Language):*


Whayooathdee, Photpeechon. Jackfruit (2nd edition). Nonthaburi Province, Thailand: Agriculture Lover's Printing House (70/682 Prahchaneewait Village 2, Muang District, Post Code 11000), 1988.


### *រូបភាពក្របខាងក្រៅ Cover picture:*


Forestry/Fuelwood Reserach and Development Project. 1992. *Growing Multipurpose Trees on Small Farms.* Bangkok, Thailand: Winrock International. 195 + ix pp. (including 41 species fact cards).


### *រូបភាពខ្លះដាក់ឈ្មោះអ្នកគូររួចហើយ ក្រៅពីនេះគូរដោយ*
### *លោក សោម សារ៉ាត មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមភ្នំពេញ កម្ពុជា ខែធ្នូ ឆ្នាំ 1996*

*Unless noted otherwise, all artwork by:*
Sarath, Som. Center for Social Development. Phnom Penh, Cambodia, Dec. 1996.

### *សៀវភៅផ្សេងទៀតដែលបានដកស្រង់ Other works referred to during translation:*


Purseglove, J.W. Tropical Crops: Dicotyledons (Volumes 1 and 2 combined). Singapore: Print House (Pte) Ltd, 1981.

Yaacob, Othman and Suranant Subhadrabandhu. The Production of Economic Fruits in South-East Asia. Kuala Lumpur: Oxford University Press, 1995.

Yunus, Ahmad and A. Balasubramaniam. Major Crop Pests in Peninsular Malaysia. Kuala Lumpur: Ministry of Agriculture, 1981.



### *បកប្រែដោយមន្ទីរកសិកម្មខេត្តបាត់ដំបង និងគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ ប្រទេសកម្ពុជា ថវិកាដែលឧបត្ថម្ភដោយកម្មវិធីសិលា*

*Translation by the Battambang Provincial Department of Agriculture and the Cambodia Northwest Provinces Fruit Culture Development Committee. Financial support provided by the SEILA Programme.*

*Computer file:* TREEBK3.DOC

### *បោះពុម្ពលើកទីមួយ (ខែមករា ឆ្នាំ 1997) 500 ក្បាល*

*First Printing (January 1997): 500 copies*



### *ហាមថតចម្លង និងហាមលក់បើគ្មានការអនុញ្ញាតពីមន្ទីរកសិកម្មខេត្តបាត់ដំបង*

***This book is not for sale nor to be re-printed without consent of the Author or the Battambang Provincial Department of Agriculture.***